# រឿងរ៉ាវរបស់ជនរងគ្រោះខ្មែរ ក្នុងវិវាទព្រំដែន ឆ្នាំ២០២៥

# Stories of Khmer Victims along Border Disputes 2025



February 2026

# មាតិកា


អារម្ភកថា .................... 2
សេចក្តីថ្លែងអំណរគុណ .................... 3
១. រឿងរ៉ាវពីជំរំជនភៀសសឹក .................... 4
១.១. ជនភៀសសឹកក្នុងខេត្តព្រះវិហារ .................... 4
១.២. ជនភៀសសឹកនៅខេត្តសៀមរាប .................... 6
២. រឿងរ៉ាវពីសហគមន៍ជនរងគ្រោះ .................... 10
២.១. ឃុំ/ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ .................... 10
២.២. ឃុំមរកត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ .................... 12
២.៣. ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ .................... 14
២.៤. សង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ .................... 15
២.៥. ឃុំគោកខ្ពស់ ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ .................... 16
៣. រឿងរ៉ាវដកស្រង់ចេញពីបណ្តាញសង្គម .................... 19
៣.១. អំពើហិង្សាផ្លូវភេទក្នុងអំឡុងពេលស្ថានភាពតានតឹង .................... 19
៣.២. ប្រជាពលរដ្ឋផ្លាស់ទីលំនៅ .................... 20
៣.៣. ការបាញ់ផ្លោងមកលើប្រជាជនស៊ីវិលនៅកម្ពុជា .................... 27
៣.៤. ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចរបស់ពលរដ្ឋខ្មែរតាមជាយដែន .................... 28
៣.៥. ផលប៉ះពាល់ពីផ្សែងពុល .................... 31
៣.៦. ហេដ្ឋារចនាសម្ព័ន្ធបានបំផ្លាញ ការបិទខ្ទប់ និងការបាត់បង់ទ្រព្យសម្បត្តិ .................... 33
៣.៧. ការប្រើប្រាស់សម្តីស្អប់ខ្ពើមលើបណ្តាញសង្គម .................... 37
៣.៨. ការបំផ្លិចបំផ្លាញបេតិកភណ្ឌ និងទីសក្ការៈបូជា .................... 41
៣.៩. អំពីការឆបោក .................... 44
៣.១០. សកម្មភាពហិង្សា និងការរឹបអូសទ្រព្យសម្បត្តិ .................... 46
៣.១១. ការបាត់បង់ដែនអធិបតេយ្យភាព .................... 48
៤. ទស្សនៈយល់ឃើញចំពោះជម្លោះធំៗទាំងពីរក្នុងឆ្នាំ ២០២៥ .................... 52
៥. ប្រវត្តិសង្ខេបនៃការបាត់បង់ .................... 53

# អារម្ភកថា

តាមរយៈការបង្ហាញនូវសៀវភៅ **«រឿងរ៉ាវរបស់ជនរងគ្រោះខ្មែរក្នុងវិវាទព្រំដែនឆ្នាំ២០២៥»** នេះ យើងត្រូវបានរំលឹកថា ប្រវត្តិសាស្ត្រមិនមែនត្រូវបានកត់ត្រាទុកត្រឹមតែនៅក្នុងសន្ធិសញ្ញាផែនទី និងការចរចានយោបាយប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវបានកត់ត្រាទុកក្នុងជីវិតរបស់ប្រជាជនសាមញ្ញ ដែលសំឡេងរបស់ពួកគេជារឿយៗ ត្រូវបានគេបំភ្លេចចោល។ នៅតាមបណ្តោយព្រំដែនដែលមានជម្លោះ គ្រួសារខ្មែររាប់មិនអស់បានស៊ូទ្រាំនឹងការភៀសខ្លួន ការបាត់បង់ និងភាពមិនច្បាស់លាស់ក្នុងជីវិត ដែលរឿងរ៉ាវរបស់ពួកគេត្រូវបានបិទបាំង ពីជម្លោះដ៏ធំធេងទាំងនោះ។

សៀវភៅនេះមានគោលបំណងលើកកម្ពស់សេចក្តីថ្លៃថ្នូរ រួមគ្នាបន្លឺសំឡេងដែលមិនត្រូវបានលើកឡើងទាំងនោះ តាមរយៈការចងក្រងនូវបទពិសោធន៍ ការចងចាំ និងការតស៊ូរបស់ពួកគេ។ នេះមិនមែនត្រឹមតែជាការកត់ត្រា នូវទុក្ខវេទនានោះទេ ប៉ុន្តែគឺជាសក្ខីភាពនៃភាពធន់ ភាពក្លាហាន និងស្មារតីមនុស្សជាតិដែលនៅតែបន្តរឹងមាំ ទោះបីជាត្រូវប្រឈមមុខនឹងភាពអយុត្តិធម៌ក៏ដោយ។ តាមរយៈការអាននូវកំណត់ត្រាទាំងនេះ លោកអ្នកនឹងត្រូវបានអញ្ជើញឱ្យសម្លឹងមើលឱ្យលើសពីភាពស្រពិចស្រពិលនៃភូមិសាស្ត្រនយោបាយ ហើយមកទទួលស្គាល់នូវតម្លៃនៃការបាត់បង់របស់មនុស្សជាតិដែលកើតចេញពីជម្លោះមិនទាន់ដោះស្រាយ។

សូមឱ្យការចងក្រងនេះ ក្លាយជាអនុស្សាវរីយ៍សម្រាប់ជនរងគ្រោះ និងជាការដាស់តឿនសតិសម្បជញ្ញៈសម្រាប់អ្នកដែលជឿជាក់លើវិបុលភាព សន្តិភាព និងអំណាចនៃការពិត។ ឆ្នាំ២០២៥ មិនត្រឹមតែជាឆ្នាំដែលឆ្លុះបញ្ចាំងពីការបន្តនៃជម្លោះប៉ុណ្ណោះទេ ប៉ុន្តែក៏ជាឱកាសសម្រាប់ការត្រិះរិះពិចារណា ការបង្រួបបង្រួមជាតិ និងការប្តេជ្ញាចិត្តជាថ្មីក្នុងការធានាថា គ្មានសំឡេងណាមួយត្រូវបានគេបំភ្លេចចោលឡើយ នៅតាមបណ្តោយព្រំដែននៃភាពស្ងៀមស្ងាត់នេះ។

សៀវភៅនេះចងក្រងឡើង ដើម្បីផ្តល់ជាសំឡេងក្នុងការបង្ហាញចេញនូវបញ្ហាប្រឈមនានារបស់សហគមន៍នៅក្នុងតំបន់ជម្លោះ និងតាមបណ្តាញសង្គម តាងនាមអោយជនរងគ្រោះខ្មែរនៅតាមបណ្តោយព្រំដែនដែលមានវិវាទ ដើម្បីឱ្យគេបានឮពីការលំបាករបស់ពួកគេដែលបានស៊ូទ្រាំនឹងការភៀសខ្លួន ភាពក្រីក្រលំបាក និងការដែលមិនត្រូវបានគេមើលឃើញ ខណៈដែលជីវិតរបស់ពួកគេត្រូវបានបាំងជិតដោយជម្លោះនយោបាយ និងវិវាទទឹកដី។ ជារឿយៗ ទុក្ខវេទនារបស់ពួកគាត់ត្រូវបានគេកាត់បន្ថយមកត្រឹមតែជាតួលេខស្ថិតិ ឬត្រូវបានគេបំភ្លេចចោលតែម្តង។

តាមរយៈការប្រមូលផ្តុំ និងការបង្ហាញនូវសក្ខីកម្មទាំងនេះ រឿងរ៉ាវនេះមានគោលបំណងលាតត្រដាងនូវការពិត រក្សាទុកនូវការចងចាំ និងរំលឹកថាបទពិសោធន៍របស់ជនរងគ្រោះមិនត្រូវបានលុបបាត់ពីប្រវត្តិសាស្ត្រឡើយ ហើយក៏ដើម្បីការពារកុំឱ្យរឿងរ៉ាវទាំងនេះកើតឡើងសារជាថ្មីម្តងទៀត។ នេះគឺជាការអំពាវនាវឱ្យមានការទទួលស្គាល់នូវតម្លៃនៃការបាត់បង់របស់មនុស្សជាតិដែលបង្កឡើងដោយជម្លោះតាមជាយដែន និងការទទួលស្គាល់ថា សន្តិភាព និងយុត្តិធម៌ ត្រូវតែចាប់ផ្តើមឡើងដោយការស្តាប់ទៅកាន់អស់អ្នកដែលបានរងនូវបន្ទុកធ្ងន់ធ្ងរបំផុតដោយសារសង្គ្រាមនេះ។ សៀវភៅនេះមានវត្តមានឡើង ព្រោះថាភាពស្ងៀមស្ងាត់មិនមែនជាអ្វីដែលយើងអាចទទួលយកបានទៀតនោះទេ ហើយក៏ថាឆ្នាំ២០២៥ ត្រូវតែជាចំណុចរបត់មួយក្នុងការចងចាំ ការកត់ត្រា និងការឆ្លើយតបទៅនឹងសំឡេងរបស់ប្រជាជនខ្មែរនៅតាមតំបន់ព្រំដែន។

# សេចក្តីថ្លែងអំណរគុណ

សៀវភៅនេះមិនអាចលេចរូបរាងឡើងបានទេ ប្រសិនបើគ្មានភាពក្លាហានរបស់ជនរងគ្រោះខ្មែរ ដែលបានសម្រេចចិត្តចែករំលែកបទពិសោធន៍របស់ពួកគាត់ ទោះបីជាត្រូវឆ្លងកាត់ភាពសៀមស្ងាត់ និងការលំបាកអស់រយៈពេលជាច្រើនឆ្នាំក៏ដោយ។ ភាពធន់របស់ពួកគាត់ក្នុងការប្រឈមមុខនឹងការភៀសខ្លួន អំពើហិង្សា និងភាពមិនច្បាស់លាស់ក្នុងជីវិត គឺជាសក្ខីភាពបញ្ជាក់ពីភាពរឹងមាំផ្នែកស្មារតីនៃប្រជាពលរដ្ឋខ្មែរ។ រាល់រឿងរ៉ាវដែលបានដាក់បញ្ចូលក្នុងសៀវភៅនេះ មិនត្រឹមតែជាកំណត់ត្រានៃទុក្ខវេទនានោះទេ ប៉ុន្តែក៏ជាការប្រកាសពីសេចក្តីថ្លៃថ្នូរ ដែលរំលឹកយើងថា ទោះបីស្ថិតក្នុងតំបន់ដែលមានជម្លោះខ្លាំងបំផុតក៏ដោយ ក៏គុណតម្លៃមនុស្សជាតិនៅតែបន្តរស់រាន។

អង្គការ **ក្រុមការងារដើម្បីដោះស្រាយទំនាស់(ក.ដ.ទ)** សូមថ្លែងអំណរគុណយ៉ាងស្មោះចំពោះការចូលរួមផ្តល់សម្ភាសន៍ដល់មន្ត្រីនៃអង្គការ **ក.ដ.ទ** នៅក្នុងការចូលរួមសង្កេតរួមគ្នាដែលបានធ្វើឡើងក្នុងខេត្តព្រះវិហារ ឧត្តរមានជ័យ និងសៀមរាប ចាប់ពីខែសីហា ដល់ខែធ្នូ ឆ្នាំ២០២៥។ ការចូលរួមយ៉ាងសកម្ម និងការរួមចំណែកដ៏មានតម្លៃរបស់ពួកគេ ក្នុងអំឡុងពេលនៃការប្រមូលមតិទាំងពីរលើក បានបង្កើនគុណភាពនៃទិន្នន័យដែលប្រមូលបានជាក់ស្តែង និងបានពង្រឹងលទ្ធផលរួមនៃការសិក្សានេះឱ្យកាន់តែទូលំទូលាយ។ ការប្តេជ្ញាចិត្តដែលបង្ហាញដោយ ក.ដ.ទ ឆ្លុះបញ្ចាំងពីការលះបង់រួមគ្នាចំពោះការស្រាវជ្រាវសហការ ហើយវាគឺជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់ជាទុនដល់ការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយព័ត៌មានគ្រប់ជ្រុងជ្រោយនាពេលអនាគត។

យើងក៏សូមថ្លែងអំណរគុណផងដែរដល់បុគ្គលិករបស់ ក.ដ.ទ ក្រុមគ្រួសារ សមាជិកសហគមន៍ និងអ្នកតស៊ូមតិទាំងឡាយ ដែលបានគាំទ្រដល់ដំណើរការនៃការប្រមូលសក្ខីកម្មទាំងនេះ ដែលជារឿយៗត្រូវប្រឈមនឹងហានិភ័យផ្ទាល់ខ្លួន។ ការប្តេជ្ញាចិត្តរបស់ពួកគេចំពោះការពិត និងយុត្តិធម៌ បានធានាថាសម្លេងទាំងនេះនឹងមិនត្រូវបានគេបំភ្លេចចោលឡើយ។ ចំពោះអស់លោកអ្នកដែលបានរួមចំណែក មិនថាតាមរយៈការនិយាយ ការស្តាប់ ឬការរក្សាទុកនូវការចងចាំ យើងសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុត។ សៀវភៅនេះគឺជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរួមគ្នា ដើម្បីផ្តល់កិត្តិយសដល់ជនភៀសសឹក និងប្រជាពលរដ្ឋដែលរស់នៅតាមបណ្តោយព្រំដែន និងដើម្បីធានាថាសំឡេងរបស់ពួកគេនឹងលាន់ឮរន្ទឺលើសពីវិវាទទាំងឡាយដែលព្យាយាមបំបិទពួកគេ ក៏ដូចជានាំមកនូវយុត្តិធម៌ និងសន្តិភាពកាន់តែប្រសើរឡើង សម្រាប់មនុស្សជាតិទាំងអស់។

# ១. រឿងរ៉ាវពីជំរំជនភៀសសឹក

## ១.១. ជនភៀសសឹកក្នុងខេត្តព្រះវិហារ

នៅចន្លោះថ្ងៃទី១០ ដល់ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៥ រឿងរ៉ាវសង្ខេបៗដែលត្រូវបានប្រមូលពីជំរំជនភៀសសឹកក្នុងខេត្តឧត្តរមានជ័យ ព្រះវិហារ និងសៀមរាប បានលាតត្រដាងនូវតថភាពដ៏លំបាកដែលគ្រួសារភៀសសឹក (បាត់បង់ទីលំនៅ) កំពុងប្រឈមមុខ។ មនុស្សជាច្រើនបានរៀបរាប់ពីការឈឺចាប់ផ្លូវចិត្ត នៃការបាត់បង់ផ្ទះសម្បែង និងដីស្រែចំការ ដោយសារភាពតានតឹងនៅតាមបណ្តោយព្រំដែន ខណៈដែលអ្នកផ្សេងទៀតបានលើកឡើងពីភាពមិនច្បាស់លាស់នៃការរស់នៅដោយគ្មានប័ណ្ណកម្មសិទ្ធិដីធ្លីច្បាស់លាស់ ឬគ្មានមុខរបរចិញ្ចឹមជីវិតដែលមានស្ថេរភាព។ ក្នុងខេត្តឧត្តរមានជ័យ គ្រួសារជាច្រើនបានរៀបរាប់ពីសម្ពាធនៃការរស់នៅក្នុងជម្រកដែលមានមនុស្សកកកុញខ្លាំង និងការទទួលបានស្បៀងអាហារ ក៏ដូចជាឱសថព្យាបាលជំងឺនៅមានកម្រិត។ ក្នុងខេត្តព្រះវិហារ ប្រជាពលរដ្ឋបានចែករំលែកនូវរឿងរ៉ាវនៃការបែកបាក់ពីសាច់ញាតិ និងការភ័យខ្លាចចំពោះការផ្ទុះឡើងវិញនូវការប៉ះទង្គិចគ្នានៅតាមតំបន់ព្រំដែន។ ទន្ទឹមនឹងនេះដែរ ក្នុងខេត្តសៀមរាប សហគមន៍ភៀសសឹក បានគូសបញ្ជាក់ពីបន្ទុកនៃបំណុល និងការតស៊ូព្យាយាមដើម្បីកសាងជីវិតឡើងវិញដែលនៅឆ្ងាយពី ដីដូនតារបស់ពួកគេ។ ជារួមរឿងរ៉ាវទាំងនេះមិនត្រឹមតែបង្ហាញពីតម្លៃនៃការបាត់បង់របស់មនុស្សជាតិដែលបង្កឡើងដោយជម្លោះប៉ុណ្ណោះទេ ប៉ុន្តែក៏បានបង្ហាញពីភាពធន់របស់អ្នកដែលកំពុងខិតខំប្រឹងប្រែងដើម្បីរស់រានមានជីវិត ចំពេលមានការភៀសខ្លួន និងការលំបាកខ្លាំងបែបនេះ។[1]



រូបភាពទី១៖ ជនភៀសសឹកនៅវត្តពោធិ៍ ៥០០០ ក្នុងខេត្តព្រះវិហារ

ពេលខ្ញុំមកដល់ទីនេះដំបូង វាមានអារម្មណ៍ថាពិបាកខ្លាំងណាស់ ព្រោះវាមិនមានអ្វីទាំងអស់ ហើយភ្លៀងធ្លាក់ខ្លាំងធ្វើឱ្យការធ្វើដំណើរទៅណាមកណាមានការលំបាក ដោយសារតែមិនទាន់មាន តង់ និងសម្ភារៈផ្សេងៗ។ ទាល់តែ ២ ឬ ៣ ថ្ងៃក្រោយមក ទើបគេផ្តល់តង់ឱ្យខ្ញុំ។ ពេលខ្ញុំមកដល់ទីនេះដំបូង ភ្លៀងធ្លាក់មិនឈប់ទាល់តែសោះ ហើយផ្លូវក៏ត្រូវលិចទឹកអស់ដែរ។ ខ្ញុំបានរត់ចុះរត់ឡើង ឱបកូនៗ ហើយដាក់ពួកគេចូលទៅក្នុងលេណដ្ឋាន នៅពេលដែលខ្ញុំឮសូរគ្រាប់បែកកំពុងទម្លាក់មក។ នៅពេលនោះ ប្តីរបស់ខ្ញុំមិនបាននៅទីនេះទេ គាត់បានបើកត្រាក់ទ័រចូលទៅក្នុងព្រៃ ដែលធ្វើអោយខ្ញុំពិបាករកទីពឹង។

[1] https://www.youtube.com/watch?v=js4Siwesmv4
https://www.youtube.com/watch?v=e9goR4lfs00



រូបភាពទី ២៖ ជនភៀសសឹកនៅវត្តឧត្តរគិរីទួលអណ្ដែត ហៅវត្តថ្មល់បំបែក ក្នុងខេត្តព្រះវិហារ

ខ្ញុំចាស់ហើយ មិនខ្លាចស្លាប់ទេ។ ខ្ញុំរត់មកទីនេះតែម្នាក់ឯង។ ខ្ញុំបារម្ភពីកូនៗរបស់ខ្ញុំ ដែលជាទាហាននៅភ្នំខ្មោចជាកន្លែងដែលមានការប្រយុទ្ធគ្នានៅសមរភូមិមុខ ខ្ញុំបាត់ដំណឹងពីពួកគេ ខ្ញុំបារម្ភពីសុវត្ថិភាពរបស់ពួកគេខ្លាំងណាស់។



រូបភាពទី ៣៖ ជនភៀសសឹកនៅវត្តឧត្តរគិរីទួល អណ្ដែត ហៅវត្តថ្មល់បំបែក ក្នុងខេត្តព្រះវិហារ

មេឃកំពុងភ្លៀងនៅពេលដែលយើងកំពុងរត់។ ពួកខ្ញុំមិនទាន់បានមកដល់វត្តនៅឡើយទេ។ ពួកខ្ញុំបានឈប់សម្រាកនៅពាក់កណ្ដាលផ្លូវ ហើយសុំអ្នកនៅទីនោះស្នាក់នៅមួយយប់ ប៉ុន្តែខ្ញុំដេកមិនលក់ទាល់តែសោះ ដោយសារតែការភ័យខ្លាច ការព្រួយបារម្ភ និងមូសខាំ។



រូបភាពទី ៤៖ ជនភៀសសឹកនៅវត្តឧត្តរគិរីទួល អណ្ដែត ហៅវត្តថ្មល់បំបែក ក្នុងខេត្តព្រះវិហារ

ខ្ញុំបានរត់មកទីនេះ គឺមកជំរំជនភៀសសឹក បន្ទាប់មកខ្ញុំក៏បានត្រឡប់ទៅផ្ទះវិញជាមួយចៅរបស់ខ្ញុំ។ ពីរថ្ងៃក្រោយមក ខ្ញុំបានឮគេប្រកាសអំពីផ្សែងពុល ខ្ញុំក៏នាំចៅៗរត់ត្រឡប់មកទីនេះវិញ យើងខ្លាចណាស់។ ខ្ញុំមានអារម្មណ៍ថាមិនមានសុវត្ថិភាពទាល់តែសោះ ហើយរស់តែរត់ចុះរត់ឡើងបែបនេះ មិនអាចរកប្រាក់កាសដើម្បីជីវភាពគ្រួសារបានឡើយ។



រូបភាពទី ៥៖ ជនភៀសសឹកនៅវត្តឧត្តរគិរីទួល អណ្ដែត ហៅវត្តថ្មល់បំបែក ក្នុងខេត្តព្រះវិហារ

ខ្ញុំខ្លាចគ្រាប់បែក និងគ្រាប់កាំភ្លើងដែលធ្លាក់មកដូចភ្លៀងនៅលើដំបូលផ្ទះ នៅថ្ងៃនោះយើងបានរត់ទៅកាន់លេណដ្ឋានដែលនៅក្បែរនោះ គ្រាប់បែកបានធ្លាក់នៅជិតៗ និងជុំវិញផ្ទះ ព្រមទាំងស្រែចំការរបស់ខ្ញុំ។ ខ្ញុំមកស្នាក់នៅវត្តនេះ ពួកខ្ញុំទទួលបានស្បៀងអាហារគ្រប់គ្រាន់ពីសប្បុរសជន ប៉ុន្តែពួកខ្ញុំបារម្ភពីផ្ទះសម្បែង និងស្រែចំការរបស់ពួកខ្ញុំដែលមិនអាចប្រមូលផលបាន។

ខ្ញុំឮសូរគ្រាប់បែកធ្លាក់ពេលកំពុងបោសសម្អាត ខ្ញុំក៏ទម្លាក់អំបោសចោល រួចរត់ទៅប្រមូលខោអាវ។ នៅពេលនោះ កូនៗរបស់ខ្ញុំនៅភ្នំពេញបារម្ភពីខ្ញុំខ្លាំងណាស់ ព្រោះខ្ញុំមិនបានទទួលទូរសព្ទ មិនបានឆ្លើយឆ្លងតាមឆាត ឬសារ។ ក្រោយមក ខ្ញុំបានប្រាប់ពួកគេថា ខ្ញុំរវល់តែរត់គេចពីតំបន់វាយប្រហារ ប៉ុន្តែខ្ញុំមិនដឹងថាត្រូវទៅទីណាទេ។ ខ្ញុំប្រាប់ពួកគេថា កុំបារម្ភពីខ្ញុំអី ខំប្រឹងធ្វើការទៅ។



*រូបភាពទី ៦៖ ជនភៀសសឹកនៅវត្តឧត្តរគិរីទួល អណ្ដែត ហៅវត្តថ្មលំបំបែក ក្នុងខេត្តព្រះវិហារ*

## ១.២. ជនភៀសសឹកនៅខេត្តសៀមរាប



*រូបភាពទី ៧៖ ជនភៀសសឹកនៅវត្តប្រាសាទបទុមមួង ក្នុងស្រុកស្រីស្នំ ខេត្តសៀមរាប*

ខ្ញុំខ្លាចរហូតដល់ញ័រខ្លួនក្នុងពេលរត់ ព្រោះខ្ញុំខ្លាចសូរគ្រាប់បែកដែលផ្ទុះខ្លាំងៗ និងសូរគ្រាប់កាំភ្លើង។ ខ្ញុំខ្លាចរហូតដល់ដកដង្ហើមមិនចង់រួច ខ្ញុំបានរត់មកទីនេះទាំងកណ្ដាលយប់ ទាំងរងាញាក់ដោយសារតែភ្លៀងធ្លាក់ និងធាតុអាកាសត្រជាក់។ ខ្ញុំមានអារម្មណ៍ថាមិនស្រួលខ្លួន និងកំពុងធ្លាក់ខ្លួនឈឺ។ ខ្ញុំព្រួយបារម្ភ ហើយមិនដឹងថាពេលណាទើបពេលវេលាដ៏ខ្មៅងងឹតនេះបញ្ចប់ទៅនោះទេ។ ខ្ញុំធ្លាប់ឆ្លងកាត់បទពិសោធន៍សង្គ្រាម ហើយខ្ញុំមិនចង់ឱ្យវាកើតឡើងម្តងទៀតឡើយ។

ខ្ញុំខ្លាចខ្លាំងណាស់ ខ្ញុំដេកមិនលក់ ហើយក៏គ្មានអ្វីហូបដែរនៅពេលរត់មកទីនេះ ព្រោះខ្ញុំមិនអាចយកអ្វីតាមខ្លួនបានឡើយ ដោយសារតែខ្លាចសូរគ្រាប់បែកផ្ទុះខ្លាំងពេក។ អ្វីដែលខ្ញុំគិតនៅពេលនោះ គឺត្រូវតែរត់ទៅជាមួយអ្នកដទៃដើម្បីរកកន្លែងដែលមានសុវត្ថិភាព ហើយនៅពេលមកដល់ទីនេះ ខ្ញុំគ្មានសម្ភារៈសម្រាប់ស្នាក់នៅ ឬសម្រាប់ចម្អិន ហូបចុកអ្វីទាំងអស់។



*រូបភាពទី ៨៖ ជនភៀសសឹកនៅវត្តប្រាសាទបទុមមួង ក្នុងស្រុកស្រីស្នំ ខេត្តសៀមរាប*



*រូបភាពទី ៩៖ ជនភៀសសឹកនៅវត្តប្រាសាទបទុមមួង ក្នុងស្រុកស្រីស្នំ ខេត្តសៀមរាប*

ខ្ញុំបានរត់គេចខ្លួនបែបនេះពីរបីដងរួចមកហើយ រួចក៏ត្រឡប់ទៅផ្ទះវិញ។ ប៉ុន្តែខ្ញុំដេកនៅផ្ទះមិនលក់ឡើយ ព្រោះខ្ញុំខ្លាចដ្រូន ដែលហោះហើរពេញផ្ទៃមេឃ។ ខ្ញុំបានធ្លាក់ខ្លួនឈឺ និងក្តៅខ្លួនខ្លាំង។ ប៉ុន្តែនៅពេលដែលកូនៗបញ្ជូនខ្ញុំមកទីនេះជាលើកទីបី ទើបខ្ញុំអាចហូបចុក និងសម្រាកលក់បានខ្លះ។

ខ្ញុំមិនចង់រត់គេចមកទីនេះទេ។ វាពិបាកទាំងការរស់នៅ ការដេក និងការហូបចុក គឺវាមិនមានភាពងាយស្រួលទាល់តែសោះ។ ផ្ទះសម្បែងរបស់ខ្ញុំគឺមានភាពកក់ក្ដៅជាងការរស់នៅទីនេះឆ្ងាយណាស់។ ប៉ុន្តែដោយសារផ្ទះរបស់ខ្ញុំស្ថិតនៅក្នុងតំបន់មានជម្លោះ ខ្ញុំក៏ត្រូវបានបង្ខំចិត្តឱ្យចាកចេញពីផ្ទះដ៏មានសេចក្ដីសុខរបស់យើង។



*រូបភាពទី ១០៖ ជនភៀសសឹកនៅវត្តប្រាសាទបទុមមួង ក្នុងស្រុកស្រីស្នំ ខេត្តសៀមរាប*



*រូបភាពទី ១១៖ ជនភៀសសឹកនៅខេត្តសៀមរាប*

មានគ្រាប់កាំភ្លើងធ្លាក់យ៉ាងខ្លាំងនៅជុំវិញផ្ទះរបស់យើងក្នុងពេលដែលកូនៗរបស់ខ្ញុំដែលរៀនថ្នាក់ទី ៤ និងថ្នាក់ទី ៦ កំពុងប្រឡងបញ្ចប់ការសិក្សា។ ការប្រឡងមិនទាន់ទាំងបានបញ្ចប់ផងយើងក៏ត្រូវរត់គេចពីសមរភូមិ ដោយសារតែសាលារៀនក៏បានប្រកាសបិទទ្វារដែរ។ ពួកខ្ញុំត្រូវតែជម្លៀសខ្លួនទៅកាន់តំបន់ដែលមានសុវត្ថិភាព។ កូនៗបានខកខានការរៀនសូត្រអស់រយៈពេលយ៉ាងយូរ ដោយសារតែសាលារៀនត្រូវបានបំផ្លិចបំផ្លាញ។





*រូបភាពទី ១២៖ សាលារៀនត្រូវបានបំផ្លិចបំផ្លាញ កុមារបានពួនសម្ងំនៅក្នុងលេណដ្ឋានជនមានពិការភាពមិនអាចត្រឡប់ទៅផ្ទះសម្បែងរបស់ពួកគេវិញបានឡើយ។*





ខ្ញុំឈ្មោះ ស្រីដែន រត់មកពីតំបន់ស្រអែម ខេត្តព្រះវិហារ។ ផ្ទះរបស់ខ្ញុំត្រូវបានចោរសៀមបាញ់ដោយអាវុធធុនធ្ងន់ ដែលមានសម្លេងផ្ទុះខ្លាំងៗ កូនៗរបស់ខ្ញុំនាំគ្នាបង្ហូរទឹកភ្នែកយំ...។ គ្រួសាររបស់ខ្ញុំមិនអាចចេញពីក្នុងលេណដ្ឋានបានឡើយ ដោយសារតែការបាញ់បោះខ្លាំងពេក ហើយនៅពេលដែលគេប្រកាសថា ភាគីថៃបានបាញ់ផ្សែងពុល យើងក៏ត្រូវតែរត់គេចខ្លួន។ ផ្ទះរបស់ឪពុកម្តាយ និងសាច់ញាតិរបស់ខ្ញុំត្រូវបានទុកចោល និងចាក់សោចោលទាំងអស់ ប្រសិនបើស្ថានភាពធូរស្រាល យើងនឹងត្រឡប់ទៅមើលផ្ទះវិញ ព្រោះវាធ្វើពីឈើ ខ្ញុំបារម្ភខ្លាចមានអំពើចោរកម្ម និងបារម្ភពីសត្វពាហនៈព្រមទាំងទ្រព្យសម្បត្តិរបស់ខ្ញុំ ព្រោះមានផ្ទះជាច្រើនបានបាត់បង់ទ្រព្យសម្បត្តិអស់យ៉ាងច្រើន។ ខ្ញុំខ្លាចខ្លាំងណាស់ ព្រោះសម្លេងកាំភ្លើង និងគ្រាប់បែកលាន់ឮខ្លាំងៗ កូនៗភ័យយំ រីឯពួកយើងក៏រត់ចូលលេណដ្ឋានទាំងមិនដឹងថាត្រូវទៅទីណា។ ក្នុងអំឡុងពេលប្រយុទ្ធគ្នា ខ្ញុំហូបមិនបាន ដេកមិនលក់ឡើយ ដោយសារតែភាពភ័យស្លន់ស្លោ អ្នកជិតខាងរបស់ខ្ញុំបានរត់គេចខ្លួនអស់ ភូមិរបស់យើងចាប់ផ្តើមស្ងាត់ជ្រងំគ្មានមនុស្សរស់នៅឡើយ សល់តែខ្ញុំ និងកូនៗដែលសម្ងំនៅក្នុងលេណដ្ឋាន ព្រោះគ្មានមធ្យោបាយធ្វើដំណើរដើម្បីរត់គេច។



រូបភាពទី ១៣៖ ជនភៀសសឹក នៅខេត្តសៀមរាប

ក្នុងអំឡុងពេលប្រយុទ្ធគ្នា មានការបាញ់បោះទាំងគ្រាប់កាំភ្លើងធំ និងតូច ដែលបង្កឱ្យមានការភ័យខ្លាចជាបន្តបន្ទាប់។ ខ្ញុំតក់ស្លុតខ្លាំងណាស់ នៅពេលដែលគ្រាប់បែកមួយគ្រាប់ ដែលមានប្រវែងជិតពីរម៉ែត្រ បានធ្លាក់មកនៅក្បែរផ្ទះរបស់ខ្ញុំ។ សំណាងល្អដែលវាមិនបានផ្ទុះ ប៉ុន្តែស្ថានីយប្រេងឥន្ធនៈមួយនៅក្បែរនោះត្រូវបានបំផ្លិចបំផ្លាញ។ ហេតុការណ៍នេះបានធ្វើឱ្យខ្ញុំរន្ធត់ចិត្តយ៉ាងខ្លាំង ព្រោះវាមិនដែលមានសង្គ្រាម ឬអំពើហិង្សាដែលកើតឡើងភ្លាមៗដូចនេះទេ ហេតុការនេះបាននាំមកនូវអារម្មណ៍ភ័យខ្លាច និងអសន្តិសុខសារជាថ្មីម្តងទៀត។



រូបភាពទី ១៤៖ ជនភៀសសឹកនៅខេត្តសៀមរាប





រូបភាពទី ១៥៖ គ្រាប់រ៉ុក្កែត និងផ្ទះសម្បែងដែលត្រូវបានបំផ្លាញ



រូបភាពទី ១៦៖ ជនភៀស សឹកនៅខេត្តសៀមរាប

ក្នុងអំឡុងពេលប្រយុទ្ធគ្នាយ៉ាងខ្លាំងក្លានៅថ្ងៃទី២៤ ខែកក្កដា ខ្ញុំមិនអាចទាក់ទងកូនៗទាំងពីរនាក់របស់ខ្ញុំបានទេ ខ្ញុំបារម្ភពីពួកគេខ្លាំងណាស់ព្រោះពួកគេធ្វើការនៅព្រំដែនអូរស្មាច់ ទីនោះគ្មានសេវាទូរសព្ទ ខ្ញុំហៅពួកគេមិនចូលឡើយ។ ប៉ុន្មានថ្ងៃក្រោយមក ទើបពួកគេទាក់ទងមកខ្ញុំវិញ ពួកយើងបានត្រឹមតែយំតាមទូរសព្ទ និងមានភាពភ័យខ្លាចខ្លាំង ដោយសារគ្រាប់បែកបានធ្លាក់នៅក្បែរផ្ទះ និងកន្លែងធ្វើការរបស់យើង។ ពួកខ្ញុំបានបួងសួងសុំសេចក្តីសុខ ហើយខ្ញុំចង់នាំកូនៗទាំងអស់ត្រឡប់មកជួបជុំគ្នា នៅជំរំជនភៀសខ្លួនក្នុងខេត្តសៀមរាបនេះណាស់ ប៉ុន្តែមិនអាចធ្វើដំណើរបានឡើយ ដោយសារចាស់ទុំនៅទីនោះមិនអនុញ្ញាតឱ្យពួកគេមក ព្រោះមិនមានសុវត្ថិភាព (កូនម្នាក់អាយុ ៨ ឆ្នាំ និងម្នាក់ទៀតអាយុ ១៧ ឆ្នាំ)។

នៅពេលដែលមានកិច្ចព្រមព្រៀងឈប់បាញ់ ភាគីទាំងពីរបានផ្អាកការប្រយុទ្ធគ្នា ប៉ុន្តែកងទ័ពថៃនៅតែប្រើប្រាស់អាវុធជំពាមកៅស៊ូ បាញ់មកលើទាហានខ្មែរដើម្បីឌឺដង រីឯទាហានកម្ពុជាក៏ប្រើប្រាស់អាវុធជំពាមកៅស៊ូ តបតទៅវិញដែរ។ នៅពេលខ្ញុំមកដល់ជំរំជនភៀសខ្លួននេះ រាជរដ្ឋាភិបាលបានផ្តល់ស្បៀងអាហារ ទឹក និងអគ្គិសនីគ្រប់គ្រាន់ ប៉ុន្តែគ្រួសាររបស់ខ្ញុំត្រូវនៅបែកបាក់គ្នាតាមតំបន់ផ្សេងៗគ្នា គឺកូនៗរបស់ខ្ញុំនៅអូរស្មាច់ ប្តីរបស់ខ្ញុំនៅព្រះវិហារ ចំណែកខ្ញុំត្រូវជម្លៀសមកទីនេះក្នុងខេត្តសៀមរាប ហើយពួកយើងតែងតែបារម្ភពីសុវត្ថិភាពគ្នាទៅវិញទៅមកក្នុងកំឡុងពេលដែលមានការវាយប្រហារនេះ។





រូបភាពទី១៧៖ កុមារមានភាពភ័យខ្លាចនៅក្នុងលេណដ្ឋាន និងក្នុងជម្រុំជនភៀសខ្លួន។

# ២. រឿងរ៉ាវពីសហគមន៍ជនរងគ្រោះ

នៅចន្លោះថ្ងៃទី១ ដល់ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៥ រឿងរ៉ាវជាច្រើនត្រូវបានប្រមូលចងក្រងពីសហគមន៍ជនរងគ្រោះដែលត្រូវបានជ្រើសរើស ចេញពីឃុំចំនួនប្រាំក្នុងខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ ដើម្បីកត់ត្រាទុកនូវបទពិសោធន៍នៃការបង្ខំចិត្តជម្លៀសខ្លួនចេញពីផ្ទះសម្បែងទៅកាន់ជំរំបណ្ដោះអាសន្ន និងការរងទុក្ខវេទនាដោយសារការផ្លាស់ទីលំនៅដែលបង្កឡើងដោយសង្គ្រាម។

ការរៀបរាប់រឿងរ៉ាវទាំងនេះបានលាតត្រដាងពីស្ថានការអាប់អួរ ដែលប៉ះពាល់យ៉ាងខ្លាំងដល់ជីវភាពរស់នៅប្រចាំថ្ងៃ នៅពេលដែលក្រុមគ្រួសារនីមួយៗត្រូវបានបង្ខំឱ្យបោះបង់ចោលដីធ្លី ទ្រព្យសម្បត្តិ និងមុខរបរចិញ្ចឹមជីវិតរបស់ពួកគេ ក្រោមស្ថានភាពដ៏លំបាកបំផុត។ សក្ខីកម្មទាំងនេះបានគូសបញ្ជាក់ ពីការលំបាកផ្នែករាងកាយក្នុងការផ្លាស់ទីលំនៅ ក៏ដូចជាការធ្វើដំណើរដ៏វែងឆ្ងាយដោយថ្មើរជើង ការខ្វះខាតជម្រកស្នាក់នៅ និងការទទួលបានស្បៀងអាហារមានកម្រិត ព្រមទាំងផលប៉ះពាល់ផ្លូវចិត្តនៃការបែកបាក់ពីទីកន្លែងដែលធ្លាប់រស់នៅ និងសហគមន៍ផងដែរ លើសពីនេះ ផលប៉ះពាល់ដែលនៅសេសសល់ពីសង្គ្រាម បានបន្តជះឥទ្ធិពលដល់សុខភាព សេដ្ឋកិច្ច កសិកម្ម ការអប់រំ និងសតិអារម្មណ៍ដែលមិនមានសុវត្ថិភាពរបស់ពួកគេ។

## ២.១. ឃុំ/ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ


*ជនភៀសសឹកមកពីខេត្តព្រះវិហារ*

ចាប់តាំងពីការវាយប្រហារបានចាប់ផ្ដើមនៅថ្ងៃទី២៤ ខែកក្កដា ខ្ញុំបានជម្លៀសខ្លួនចេញពីផ្ទះនៅពាក់កណ្ដាលអាធ្រាត្រ រហូតដល់ថ្ងៃទី៣ ខែសីហា ឆ្នាំ២០២៥ ទើបខ្ញុំបានត្រឡប់មកផ្ទះវិញនៅក្នុងខេត្តព្រះវិហារ។ ខ្ញុំបានរត់ទាំងក្ដីបារម្ភ និងភ័យខ្លាច នៅពេលដែលខ្ញុំឃើញដ្រូន (Drones) ហោះហើរនៅជុំវិញ។ ពួកយើងខ្លាចណាស់ ហើយសូម្បីតែមកដល់ពេលនេះ គឺដើមខែធ្នូ ឆ្នាំ២០២៥ ទៅហើយ ក៏ខ្ញុំនៅតែមានអារម្មណ៍ភ័យខ្លាចនៅពេលឃើញដ្រូនហោះហើរ ជាពិសេសនៅពេលយប់ ប៉ុន្តែពួកយើងនៅតែបន្តខំប្រឹងធ្វើការនៅតាមចម្ការរបស់យើងដើម្បីជីវភាព។


*ជនភៀសសឹកមកពីខេត្តព្រះវិហារ*

ខ្ញុំបានបាត់បង់ជើងម្ខាង ដោយសារតែគ្រាប់មីននៅម្ដុំប្រាសាទក្នុងឃុំរបស់ខ្ញុំ កាលពីពេលដែលខ្ញុំទៅកាប់ឈើ រើសអូសដុត។ មានគ្រាប់មីនជាច្រើនរាយប៉ាយពេញព្រៃរហូតមកដល់សព្វថ្ងៃ ដែលធ្វើឱ្យការចូលទៅក្នុងព្រៃដើម្បីរកកាប់ឈើមានការលំបាកខ្លាំងណាស់។


*ជនភៀសសឹកមកពីខេត្តព្រះវិហារ*

ប្ដីរបស់ខ្ញុំក៏បានបាត់បង់ជើងម្ខាងដូចគាត់ដែរ ដោយសារតែគ្រាប់មីនរាយប៉ាយ នៅជុំវិញភ្នំ នៅពេលដែលគាត់ចូលទៅកាប់ឈើធ្វើអុស។

ក្នុងអំឡុងពេលប្រយុទ្ធគ្នាយ៉ាងខ្លាំងក្លាចាប់ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ នៅពេលដែលខ្ញុំត្រឡប់មកផ្ទះវិញ សត្វចិញ្ចឹមទាំងអស់បានងាប់អស់ទៅហើយ ដោយសារតែផ្សែងពុល។ មាន់ និងឆ្កែ បានងាប់រាយប៉ាយពេញដី និងជុំវិញផ្ទះ ដោយសារតែពុលផ្សែងទាំងនោះ។ ចំណែករូបខ្ញុំផ្ទាល់ ក៏រងផលប៉ះពាល់ពីការពុលផ្សែងនេះដែរ វាធ្វើឱ្យខ្ញុំឈឺក្បាល និងវិលមុខ មានអារម្មណ៍មិនស្រួលក្នុងទ្រូង និងស្ងួត ហើយខ្ញុំដកដង្ហើមមិនសូវស្រួលឡើយរហូតមកដល់សព្វថ្ងៃ។



ជនភៀសសឹកមកពីខេត្តព្រះវិហារ



ជនភៀសសឹកមកពីខេត្តព្រះវិហារ

នៅពេលនោះ ខ្ញុំមានកូនតូចនៅក្នុងបន្ទុក ហើយមានការភ័យខ្លាចខ្លាំងណាស់។ រូបខ្ញុំ និងអ្នកភូមិដទៃទៀត បានបាត់បង់សត្វចិញ្ចឹមនៅគ្រប់ផ្ទះទាំងអស់នៅពេលដែលពួកយើងត្រឡប់មកវិញ។ យើងមិនដឹងថាពួកវា (សត្វចិញ្ចឹម) នៅទីណាខ្លះទេ ហើយផ្ទះសម្បែងរបស់យើងក៏ត្រូវបានបំផ្លិចបំផ្លាញ ដោយមាន សម្ភារៈរាយប៉ាយ និងបាត់បង់ទ្រព្យសម្បត្តិអស់ជាច្រើន។



រូបភាពទី ១៨៖ ផ្ទះសម្បែងរបស់សហគមន៍ដែលត្រូវបានបំផ្លិចបំផ្លាញ

https://www.youtube.com/watch?v=jFECgKxiw1U

## ២.២. ឃុំមរកត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ

ចាប់តាំងពីពីរថ្ងៃមុន បន្ទាប់ពីការប្រយុទ្ធគ្នាយ៉ាងខ្លាំងក្លា កាលពីខែ កក្កដា រហូតមកដល់ដើមខែធ្នូ ឆ្នាំ២០២៥ នេះ ម្តាយ និងប្អូនស្រីរបស់ខ្ញុំដែលបានពុលផ្សែងពុលនោះ នៅមិនទាន់មានសភាពធូរស្រាលនៅឡើយទេ។ ទោះបីជាគ្រូពេទ្យឱ្យពួកគេត្រឡប់ពីមន្ទីរពេទ្យមកផ្ទះវិញក៏ដោយ ក៏ពួកគេនៅតែពិបាកដកដង្ហើម និងមានអាការក្អក ហើយសុខភាពរបស់ពួកគេកាន់តែទ្រុឌទ្រោមទៅៗ។ ចំណែកកូនៗរបស់ខ្ញុំវិញ បានរងនូវវិបត្តិផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ ពួកគេតែងតែយំ និងស្រែកខ្លាំងៗរាល់ពេលឮសម្លេងអ្វីដែលប៉ះពាល់ខ្លាំង។ ស្មារតី និងខួរក្បាលរបស់ពួកគេមិនដូចពីមុនឡើយ គឺតែងតែមានភាពស្លន់ស្លោ ទោះបីជាលែងមានសម្លេងគ្រាប់បែកផ្ទុះទៀតក៏ដោយ។



ជនភៀសសឹកមកពីខេត្តព្រះវិហារ



ជនភៀសសឹកមកពីខេត្តព្រះវិហារ

ខ្ញុំបានរៀបការតាំងពីអាយុ ១៥ ឆ្នាំ ប្តីរបស់ខ្ញុំគឺជាអ្នកផឹកស្រា និងប្រើអំពើហិង្សាមកលើរូបខ្ញុំ ទើបពួកយើងបានលែងលះគ្នានៅពេលខ្ញុំអាយុ ១៧ ឆ្នាំ។ ខ្ញុំចិញ្ចឹមកូនតែម្នាក់ឯងដោយគ្មានការងារធ្វើឡើយ។ ក្នុងអំឡុងពេលជម្លៀសខ្លួន ខ្ញុំគ្មានប្រាក់សូម្បីតែបន្តិចដើម្បីជួយចេញថ្លៃប្រេងទៅឱ្យអ្នកជិតខាង ដែលគាត់ជាអ្នកបានឱ្យខ្ញុំជិះគោរយន្តរត់ទៅជាមួយគាត់។ ខ្ញុំជំពាក់ប្រាក់ថ្លៃប្រេងពួកគេរហូតមកដល់សព្វថ្ងៃនៅមិនទាន់បានសងនៅឡើយទេ ហើយខ្ញុំក៏គ្មានប្រាក់សូម្បីតែទិញខោទឹកនោម ឱ្យកូនតូចរបស់ខ្ញុំដែរ។

ខ្ញុំខ្លាចណាស់ ផ្ទះអ្នកជិតខាងរបស់ខ្ញុំត្រូវបានកម្ទេចដោយគ្រាប់រ៉ុក្កែត ហើយពួកគេបានស្លាប់បាត់បង់ជីវិត។ ខ្ញុំភ័យខ្លាចខ្លាំងរហូតដល់ធ្លាក់ខ្លួនឈឺ ព្រោះរូបភាពផ្ទះសម្បែងដែលខ្ទេចខ្ទី និងមនុស្សស្លាប់គឺនៅជុំវិញខ្លួនខ្ញុំ និងផ្ទះរបស់ខ្ញុំ។ ខ្ញុំនៅតែមានអារម្មណ៍ស្លន់ស្លោ និងមិនស្រួលខ្លួនទាល់តែសោះរហូតមកដល់ពេលនេះ។



ជនភៀសសឹកមកពីខេត្តព្រះវិហារ



ជនភៀសសឹកមកពីខេត្តព្រះវិហារ

ខ្ញុំបារម្ភថា បន្ទាប់ពីត្រឡប់ពីជំរំជនភៀសខ្លួនមកផ្ទះវិញ ខ្ញុំបានទុកផ្ទះចោលយូរពេកហើយ។ ខ្ញុំនៅតែមានអារម្មណ៍ភ័យខ្លាចក្នុងការរស់នៅ ព្រោះសត្វពាហនៈជាច្រើនបានងាប់អស់ ហើយខ្ញុំខ្លាចថាផ្ទះរបស់ខ្ញុំនឹង លែងមានសុវត្ថិភាពសម្រាប់រស់នៅ ដូចកាលពីមុនទៀតហើយ។



ជនភៀសសឹកមកពីខេត្តព្រះវិហារ

នៅពេលដែលខ្ញុំទើបតែត្រឡប់មកពីសម្រាលកូនវិញ ការប្រយុទ្ធគ្នាយ៉ាងខ្លាំងក្លាក៏បានចាប់ផ្តើម។ គេបានសែងខ្ញុំឡើងឡាន ហើយដឹកខ្ញុំទៅកាន់លេណដ្ឋានដើម្បីជម្លៀសខ្លួន ព្រោះខ្ញុំមិនអាចដើររួចឡើយ។ ចំណែកកូនស្រីរបស់ខ្ញុំម្នាក់នេះក៏កំពុងមានផ្ទៃពោះដែរ ហើយនាងមិនទាន់សម្រាលកូននៅឡើយទេ សម្លេងគ្រាប់រ៉ុក្កែតលាន់ឮខ្លាំងណាស់ ខ្ញុំខ្លាចខ្លាំងណាស់។ សម្លេងគ្រាប់រ៉ុក្កែតនោះលាន់ដូចផ្គរលាន់ វាផ្ទុះបែកខ្ទាយអមដោយគ្រាប់កាំភ្លើងធ្លាក់មកដូចភ្លៀង រីឯមនុស្សម្នារត់ប្រសេចប្រសាចដូចខ្លែងចាប់កូនមាន់។ អ្នកជិតខាងរបស់ខ្ញុំម្នាក់ត្រូវភ្លើងឆេះរោលស្បែក ហើយនៅពេលដែលគាត់ត្រឡប់មកពីមន្ទីរពេទ្យវិញ គេបានបញ្ជូនគាត់ទៅក្នុងលេណដ្ឋាន ប៉ុន្តែគាត់ក៏បានស្លាប់នៅទីនោះទៅដោយសារតែគាំងបេះដូង និងការឈឺចាប់ខ្លាំងពេកពីរបួសរលាកដោយសារការផ្ទុះនោះ។



ជនភៀសសឹកមកពីខេត្តព្រះវិហារ

ផ្សែងពុលបានគ្របដណ្តប់គ្រប់ទីកន្លែងតាមរយៈខ្យល់អាកាស គឺផ្សែងខ្មៅពេញផ្ទៃមេឃតែម្តង។ ភ្លាមៗបន្ទាប់ពីការប្រយុទ្ធគ្នាយ៉ាងខ្លាំងក្លានៅថ្ងៃទី២៤ ខែកក្កដា ផ្សែងពុលនៅតែបន្តបាញ់រាយប៉ាយជុំវិញ ចាប់តាំងពីពេលនោះរហូតមកដល់ខែធ្នូនេះ។ ពួកយើងមិនអាចដកដង្ហើមបានស្រួលឡើយ ហើយនៅពេលដែលយកទឹកមកប្រើប្រាស់សម្រាប់បោកគក់ខោអាវ វាធ្វើឱ្យស្បែកទៅជា រមាស់ និងពុលដោយសារតែពួកយើងរស់នៅលើជួរភ្នំដងរែក។[2]




រូបភាពទី ១៩៖ ការផ្តល់ជំនួយសម្ភារៈសម្រាប់ស្ត្រីមានផ្ទៃពោះ ក្នុងខេត្តព្រះវិហារ ខែធ្នូ ឆ្នាំ២០២៥

2 https://www.youtube.com/watch?v=JYyeEQxR5qY&t=95s

# ២.៣. ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ


ជនភៀសសឹកមកពីខេត្តព្រះវិហារ

ក្នុងអំឡុងពេលស្ថានភាពតានតឹង ខ្ញុំស្លន់ស្លោខ្លាំងណាស់ រហូតដល់មិនបានយកអ្វីតាមខ្លួនឡើយ ក្រៅតែពីនាំកូនៗរត់គេចទៅរកកន្លែងដែលមាន សុវត្ថិភាព។ ម្យ៉ាងវិញទៀត ម៉ូតូរបស់ខ្ញុំក៏ខូច ហើយខ្ញុំបារម្ភខ្លាំងណាស់ពីសុវត្ថិភាពប្តីរបស់ខ្ញុំ។ ខ្ញុំនៅតែមានអារម្មណ៍តក់ស្លុតរហូតមកដល់ខែកញ្ញា និងតុលា ពីព្រោះ សូម្បីតែក្រោយពេលចុះកិច្ចព្រមព្រៀងសន្តិភាពហើយក៏ដោយ ក៏នៅតែឮសម្លេងកាំភ្លើងបាញ់នៅជុំវិញ ដែលធ្វើឱ្យយើងត្រូវតែមានការប្រុងប្រយ័ត្នខ្ពស់។ ប៉ុន្តែទាហានខ្មែរបានវាយបកវិញ ប្រសិនបើពួកយើងបាញ់តបតទៅវិញ វានឹងក្លាយជារឿងធ្ងន់ធ្ងរ ពួកយើងបានត្រឹមតែអត់ធ្មត់ ប៉ុន្តែនៅក្នុងខែតុលា វាបានចាប់ផ្តើមម្តងទៀត ដ្រូនរបស់ថៃបានហោះហើរនៅជុំវិញ ពួកយើងខ្លាចហើយក៏បានវេចខ្ចប់សម្ភារៈដើម្បីត្រៀមខ្លួនជម្លៀសជាថ្មីម្តងទៀត។


ជនភៀសសឹកមកពីខេត្តព្រះវិហារ

ខ្ញុំបានរងរបួសដោយសារតែភាពស្លន់ស្លោក្នុងអំឡុងពេលជម្លៀសខ្លួន ខ្ញុំបានទៅជួបគ្រូពេទ្យ ហើយឥឡូវនេះរបួសបានធូរស្រាលបន្តិច កាលនោះមេឃកំពុងភ្លៀងខ្លាំង មេភូមិបានជំរុញឱ្យពួកយើងជម្លៀសខ្លួន ប៉ុន្តែឡានដឹកទំនិញរបស់យើងគ្មានសាំងឡើយ យើងក៏បានព្យាយាមបូមសាំងពីម៉ាស៊ីនបូមទឹកបាន ១.៥ លីត្រ ដើម្បីធ្វើដំណើរទៅកាន់កន្លែងមានសុវត្ថិភាព។ នៅកន្លែងជម្លៀសនោះ យើងនៅតែឮសូរគ្រាប់រ៉ុក្កែតនៅក្បែរភ្នំខ្មោច យើងបានព្យាយាមសុំថ្នាំសង្កូវលេប។ គ្រាប់រ៉ុក្កែតនៅតែបន្តហោះហើរនៅជុំវិញខ្លួនយើង។ ខ្ញុំដើរមិនរួចឡើយ ពួកយើងបាននាំគ្នារត់ទៅពួននៅក្នុងឡផ្សែងជំនួសឱ្យការចុះលេណដ្ឋានវិញ។


ជនភៀសសឹកមកពីខេត្តព្រះវិហារ

សមាជិកគ្រួសារខ្ញុំទាំង ៥ នាក់ បានចម្អិនអាហារនៅក្រោមឡានដឹកទំនិញ។ កាលនោះមេឃភ្លៀងខ្លាំងណាស់នៅពេលយប់ ហើយពួកយើងបានសម្រាកដេកនៅលើឡាននោះឯង។ ខ្ញុំបានបាត់បង់អ្វីៗជាច្រើន ដូចជាមាន់ និងទាជាច្រើនរយក្បាល គឺបាត់បង់ទាំងអស់បន្ទាប់ពីត្រឡប់មកពីការជម្លៀសវិញ។ ចំណែកឯផ្ទះរបស់ខ្ញុំក៏រងការខូចខាតដែរ ប៉ុន្តែយើងគ្មានលទ្ធភាពជួសជុលវិញឡើយ ដោយសារស្ថានភាពមិនទាន់មានស្ថិរភាព ព្រោះរវល់តែរត់គេចខ្លួន គ្មានពេលប្រមូលផល ឬរកប្រាក់កាសអ្វីឡើយ ខណៈដែលយើងនៅជំពាក់បំណុលធនាគារនៅឡើយ។



*ជនភៀសសឹកមកពីខេត្តព្រះវិហារ*

ខ្ញុំបានជម្លៀសខ្លួនជាមួយកូនពីរនាក់ ដោយដៃម្ខាងពរកូន និងដៃម្ខាងទៀតបើកម៉ូតូ។ ផ្ទះម្តាយរបស់ខ្ញុំរងការខូចខាតបន្តិចបន្តួច ប៉ុន្តែផ្ទះអ្នកជិតខាងរបស់ខ្ញុំត្រូវបានបំផ្លិចបំផ្លាញស្ទើរតែទាំងស្រុង។ ចំណែកឯចម្ការរបស់យើងវិញ គឺមិនអាចប្រមូលផលអ្វីបានឡើយ មានតែស្មៅដុះគ្របដណ្តប់ពេញចម្ការតែប៉ុណ្ណោះ។[3]

## ២.៤. សន្ទាត់កូនត្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ



*ជនភៀសសឹកមកពី ខេត្តឧត្តមានជ័យ*

ពួកខ្ញុំកំពុងជាប់បំណុលធនាគារ ដោយសារតែបានខ្ចីប្រាក់គេមកដាំដំឡូងមី និងធ្វើស្រែ ប៉ុន្តែពួកយើងមិនអាចប្រមូលផលបានអស់រយៈពេល ២ ឆ្នាំមកហើយ (ខ្លះជំពាក់ ៤ លានរៀល និងខ្លះទៀត ១០ លានរៀល) ប្រសិនបើឆ្នាំនេះនៅតែមិនបានផលទៀត ខ្ញុំមិនដឹងថាត្រូវធ្វើបែបណាឡើយ។ ពួកយើងបានក្លាយជាអ្នកក្រ ដោយសារតែរវល់តែរត់ភៀសខ្លួនពីសង្គ្រាម សូម្បីតែប្រាក់ចាក់សាំងដើម្បីរត់គេចខ្លួន ក៏ត្រូវខ្ចីពីអ្នកដទៃដែរ ហើយរហូតមកដល់ពេលនេះ ក៏នៅមិនទាន់មានលទ្ធភាពសងគេវិញនៅឡើយ។ ផ្សែងពុលដែលបាញ់មកពីប្រទេសសៀមបានរីករាលដាលនៅជុំវិញតំបន់ដែលយើងរស់នៅ ធ្វើឱ្យយើងមិនអាចប្រើប្រាស់ទឹកបានឡើយ ខ្ញុំត្រូវបង្ខំចិត្តទិញទឹកសម្រាប់ប្រើប្រាស់វិញ។ អ្នកភូមិជាច្រើនត្រូវបានជម្លៀសតាមឡានដឹកទំនិញធំៗ ពួកយើងមានលេណដ្ឋានធំៗដែលអាចដាក់មនុស្សបានច្រើនគ្រួសារ ប៉ុន្តែមិនអាចប្រើប្រាស់វាបានឡើយ នៅពេលដែលមានភ្លៀងធ្លាក់មក ព្រោះវាលិចទឹក។ នៅព្រឹកថ្ងៃទី២៤ ខែកក្កដា ពួកយើងមិនអាចហូបអាហារពេលព្រឹកបានឡើយ ដោយសារតែសម្លេងផ្ទុះធ្វើឱ្យយើងស្លន់ស្លោខ្លាំងណាស់ អ្វីដែលត្រូវធ្វើនៅពេលនោះ គឺមានតែការប្រញាប់ប្រញាល់ជម្លៀសខ្លួនប៉ុណ្ណោះ។ ពួកយើងបានបាត់បង់ផលដំណាំ ដំឡូងមី និងស្រែចម្ការទាំងអស់ ដោយសារតែរវល់តែរត់គេចចេញពីតំបន់ដែលមានជម្លោះ។



*ជនភៀសសឹកមកពីខេត្តឧត្តមានជ័យ*

ខ្ញុំបានជីកលេណដ្ឋាន ហើយម្តាយរបស់ខ្ញុំបានទៅទទួលកូនៗរបស់ខ្ញុំពីខេត្តព្រះវិហារមកផ្ទះវិញ បន្ទាប់មកពួកយើងក៏បានជម្លៀសខ្លួន ប៉ុន្តែខ្ញុំបានភ្លេចយកអត្តសញ្ញាណប័ណ្ណ និងសៀវភៅគ្រួសារតាមខ្លួន។ ភូមិរបស់ខ្ញុំនៅដាច់ស្រយាល គ្មានប្រាក់សម្រាប់ធ្វើដំណើរជម្លៀសខ្លួនទៅណាឆ្ងាយឡើយ មានតែនាំគ្រួសារពួនសម្ងំនៅក្នុងលេណដ្ឋានប៉ុណ្ណោះ។ អ្នកភូមិបានរត់គេចខ្លួនអស់ ភូមិទាំងមូលប្រែជាស្ងាត់ជ្រងំ លាន់ឮតែសម្លេងគ្រាប់កាំភ្លើង និងគ្រាប់បែកផ្ទុះនៅជុំវិញខ្លួនតែប៉ុណ្ណោះ។[4]

---

[3] https://www.youtube.com/watch?v=sJifsDATRb8&t=3s

[4] https://www.youtube.com/watch?v=QNMFV5vDJ6c&t=1s

កាលនោះមានឡានដឹកទំនិញវែងៗ ជាច្រើនបានកកស្ទះនៅលើដងផ្លូវ ដោយសារតែមានមនុស្សម្នាជាច្រើនបានជម្លៀសខ្លួនយ៉ាងណែនណាន់តាន់តាប់។ ដ្រូន តែងតែហោះហើរស្ទើរតែរាល់យប់ ពួកយើងមានការភ័យខ្លាចខ្លាំងណាស់ ហើយក្មេងៗក៏មិនអាចទៅសាលារៀនដែរ។



ជនភៀសសឹកមកពីខេត្តឧត្តរមានជ័យ



រូបភាពទី ២០៖ ជំនួយសម្រាប់ស្ត្រីដែលមានកូនតូចៗ ក្នុងខេត្តឧត្តរមានជ័យ ខែធ្នូ ឆ្នាំ២០២៥

## ២.៥. ឃុំគោកខ្ពស់ ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ



ជនភៀសសឹកមកពី
ខេត្តឧត្តរមានជ័យ

ខ្ញុំបានជិះតាមឡានដឹកទំនិញរបស់អ្នកដទៃដើម្បីជម្លៀសខ្លួន ដោយយកតាមខ្លួនបានតែខោអាវជាប់នឹងខ្លួនហ្នឹងតែប៉ុណ្ណោះ ព្រោះតែការប្រញាប់ប្រញាល់រត់គេចចេញពីផ្ទះសម្បែង។ ប្តីរបស់ខ្ញុំគឺជាជនមានពិការភាពមិនអាចដើររួចឡើយ ចំណែកកូនៗរបស់ខ្ញុំវិញមានការភ័យខ្លាចរហូតដល់ញ័រខ្លួន នៅពេលដែលឮសម្លេងគ្រាប់បែកហោះកាត់ដំបូលផ្ទះ។ ខ្ញុំមិនអាចយកសម្ភារៈផ្ទះបាយអ្វីតាមខ្លួនបានឡើយ ហើយយើងបានសុំឡានគេជិះដើម្បីចាកចេញ ព្រោះយើងគ្មានមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួន។

ខ្ញុំបានជម្លៀសខ្លួនចុះឡើងៗជាច្រើនដង ក្នុងអំឡុងពេលមានការប្រយុទ្ធគ្នានៅក្នុងខែកក្កដា និងខែសីហា។ ខ្ញុំបារម្ភខ្លាំងណាស់ខ្លាចគ្មានប្រាក់សម្រាប់សងធនាគារ ព្រោះរវល់តែរត់គេចខ្លួន មិនអាចដាំដុះ ឬប្រមូលផលដំណាំអ្វីបានឡើយ សូម្បីតែអង្ករសម្រាប់ហូបក៏គ្មានដែរ។ ខ្ញុំមិនអាចធ្វើអ្វីបានទាំងអស់ ដោយសារតែខ្លាចគ្រាប់បែកធ្លាក់មកលើផ្ទះ និងស្រែចម្ការរបស់ខ្ញុំ។


ជនភៀសសឹកមកពីខេត្តឧត្តរមានជ័យ


ជនភៀសសឹកមកពីខេត្តឧត្តរមានជ័យ

ខ្ញុំមានកូនតូចៗ និងមនុស្សចាស់នៅក្នុងបន្ទុក ដែលវាពិតជាលំបាកខ្លាំងណាស់ក្នុងការជម្លៀសពួកគេចេញ ហើយខ្ញុំក៏មិនអាចដេកលក់ឡើយនៅក្នុងស្ថានភាពបែបនេះ។ ខ្ញុំបានជួបប្រទះការលំបាកជាច្រើន ដោយសារនៅពេលនោះមានភ្លៀងធ្លាក់ខ្លាំង ហើយត្រូវរស់នៅឆ្ងាយពីផ្ទះសម្បែង ដោយគ្មានសម្ភារៈប្រើប្រាស់គ្រប់គ្រាន់ដូចកាលនៅផ្ទះផ្ទាល់ខ្លួន។

កូនៗរបស់ខ្ញុំមិនអាចទៅសាលារៀនបានទេ ដោយសារតែនៅតែមានការប្រយុទ្ធគ្នា និងសម្លេងកាំភ្លើងលាន់ឮនៅឡើយ។ ខ្ញុំមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការសិក្សារបស់កូនៗខ្ញុំ ហើយស្ថានភាពសេដ្ឋកិច្ចរបស់គ្រួសារខ្ញុំក៏កំពុងជួបវិបត្តិបំណុល ដោយមិនអាចចេញទៅធ្វើការដើម្បីរកប្រាក់សងធនាគារវិញបាន ឡើយ។ ចំណែកឯចម្ការរបស់ខ្ញុំវិញ ក៏មិនអាចប្រមូលផលបានដែរនៅក្នុងកំឡុងពេលប្រយុទ្ធគ្នានេះ ដោយសារមានគ្រាប់បែកមិនទាន់ផ្ទុះជាច្រើនរាយប៉ាយនៅជុំវិញវាលស្រែចម្ការ។[5]


ជនភៀសសឹកមកពីខេត្តឧត្តរមានជ័យ


រូបភាពទី ២១៖ ជំនួយសម្រាប់ស្ត្រី និងជនមានពិការភាព ក្នុងខេត្តព្រះវិហារ ខែធ្នូ ឆ្នាំ២០២៥

5 https://www.youtube.com/watch?v=X-Y2nY8IDas



**មេឃុំគោកខ្ពស់៖** បានចែករំលែកថា មានគ្រាប់កាំភ្លើង និងគ្រាប់បែកជាច្រើន បានធ្លាក់រាយប៉ាយនៅក្នុងឃុំរបស់យើង ហើយមានគ្រាប់បែកមិនទាន់ផ្ទុះ ប្រហែល ១,០០០ គ្រាប់ នៅសេសសល់នៅឡើយ។ ដូច្នេះ សូមបងប្អូនមេត្តាប្រុងប្រយ័ត្នខ្ពស់ ខណៈដែលមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (CMAC) កំពុងធ្វើការលើបញ្ហានេះ។ ប្រជាសហគមន៍របស់យើងមិនគួរចេញទៅប្រមូលផលនៅតាមវាលស្រែឡើយ ព្រោះវាមានគ្រោះថ្នាក់ខ្លាំងណាស់។ នៅក្នុងឃុំរបស់យើងក៏កំពុងប្រឈមមុខនឹងបញ្ហាសេដ្ឋកិច្ច និងបញ្ហាកសិកម្មយ៉ាងខ្លាំងផងដែរនៅក្នុងពេលនេះ។



**អភិបាលរងស្រុកបន្ទាយអំពិល៖** ក្នុងអំឡុងពេលមានជម្លោះយ៉ាងខ្លាំងចាប់ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ ចំនួនជនភៀសខ្លួននៅក្នុងជំរំរបស់យើងបានកើនឡើងដល់៣,៨៧២ គ្រួសារ ដែលវាលើសពីសមត្ថភាពដែលយើងអាចទទួលយកបាន ជាពិសេសចំនួនស្ត្រី និងកុមារដែលមានជំងឺគ្រុនផ្តាសាយ និងគ្រុនរងាបានកើនឡើងយ៉ាងខ្លាំង។ នៅពេលនោះ វាពិតជាមានការលំបាកខ្លាំងណាស់សម្រាប់មន្ត្រីស្រុករបស់យើង ក្នុងការគ្រប់គ្រងស្ថានភាពឱ្យបានល្អប្រសើរ។







*រូបភាពទី ២២៖ ជំនួយសង្គ្រោះនៅខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ ក្នុងខែធ្នូ ឆ្នាំ២០២៥*

# ៣. រឿងរ៉ាវដកស្រង់ចេញពីបណ្ដាញសង្គម

## ៣.១. អំពើហិង្សាផ្លូវភេទក្នុងអំឡុងពេលស្ថានភាពតានតឹង

រឿងរ៉ាវដ៏រន្ធត់មួយបានលេចឡើងក្នុងអំឡុងពេលជម្លោះកម្ពុជា-ថៃ ដែលពាក់ព័ន្ធនឹងពលករចំណាកស្រុកខ្មែរម្នាក់អាយុ ១៨ ឆ្នាំ ដែលបានត្រឡប់មកពីប្រទេសថៃ ហើយបានរាយការណ៍ថានាងត្រូវបានរំលោភសេពសន្ថវៈដោយក្រុមទាហានថៃដែលស្លៀកឯកសណ្ឋានខ្មៅ។ ទោះបីជាករណីរបស់នាងមានសភាពធ្ងន់ធ្ងរ និងទទួលរងនូវការឈឺចាប់យ៉ាងខ្លាំងក៏ដោយ ក៏គ្មានការស៊ើបអង្កេតណាមួយត្រូវបានធ្វើឡើងដោយអាជ្ញាធរថៃ ឬស្ថាប័នអាស៊ានឡើយ ដែលធ្វើឱ្យជនរងគ្រោះមិនទទួលបានយុត្តិធម៌ ឬការទទួលស្គាល់។ ផ្ទុយទៅវិញ មន្ត្រីថៃបានច្រានចោលការចោទប្រកាន់នេះថាជា **«ព័ត៌មានក្លែងក្លាយ»** ដែលការបដិសេធនេះបានធ្វើឱ្យជនរងគ្រោះកាន់តែមានទុក្ខ និងបានឆ្លុះបញ្ចាំងពីបញ្ហាកាន់តែធំនៃការរួចផុតពីសំណាញ់ច្បាប់ ចំពោះករណីហិង្សាផ្លូវភេទក្នុងអំឡុងពេលមានជម្លោះ។ រឿងរ៉ាវនេះបានបញ្ជាក់យ៉ាងច្បាស់ពីការបំបិទមាត់អ្នករស់រានមានជីវិត និងតម្រូវការបន្ទាន់សម្រាប់យន្តការទទួលខុសត្រូវ និងការការពារនៅក្នុងវិវាទតំបន់[6]។



The Phnom Penh Post | Police inve

https://www.phnompenhpost.com/national/police-investigating-alleged-rape-of-returning-worker-by-thai-troops?fbc...

# Police investigating alleged rape of returning worker by Thai troops

NATIONAL

Publication date
17 November 2025 | 13:49 ICT

Reporter : **Phak Seangly**

More Topic

Interior minister Sar Sokha and his wife visit the victim of an alleged gang rape by Thai soldiers, at Battambang Provincial Hospital on November 17. Sar Sokha

Cambodian authorities are investigating a rape complaint which was filed by an 18-year-old returning migrant worker. She alleges that she was raped by a group of Thai soldiers in black uniforms as she and a group of workers crossed the

LATEST NEWS

**Cross-border donors back aid for displaced Cambodian children with 2,000 'Boxes of Hope'**

**Preparing Cambodia for the Rise of BTC and USDT Wallet-to-Wallet Scam Networks**

**Singaporean boy, 14, who simulated ISIS terror attacks on Roblox issued restriction order**

**Chinese President Xi, British PM Starmer envision growth of ties**

**South Korean former first lady gets 1 year, 8 months for church bribery**

[6] https://www.phnompenhpost.com/national/police-investigating-alleged-rape-of-returning-worker-by-thaitroops?fbclid=IwY2xjawOIyJtleHRuA2FlbQIxMABicmlkETFQQWZxYVViMVhNOU1WMXlRc3J0YwZhcHBfaWQQMjIyMDM5MTc4ODIwMDg5MgABHodBt_TqAzHEhobTUEIwcu9jgODtZeps9U3XW63qBI8g1XJNOcGVyhWSkkOh_aem_GKIjqlwqsLwybCItc0pU6g

## ៣.២. ប្រជាពលរដ្ឋផ្លាស់ទីលំនៅ





ខ្ញុំពិតជាមានទុក្ខសោកជាខ្លាំង ផ្ទះរបស់ខ្ញុំត្រូវបានបំផ្លិចបំផ្លាញ ហើយខ្ញុំបានបាត់បង់ សម្ភារៈគ្រប់យ៉ាង រួមទាំងកាបូប សៀវភៅ និងសម្លៀកបំពាក់នៅក្នុងផ្ទះដែលខ្ញុំធ្លាប់រស់នៅជាមួយ ប៉ុន្តែឥឡូវនេះវាត្រូវបានកម្ទេចអស់ទៅហើយ។ ខ្ញុំគ្មានពាក្យអ្វីនឹងថ្លែងឡើយ នៅពេលដែលឃើញផ្ទះរបស់ខ្ញុំមានសភាពបែបនេះ[7]។



**អ្នកស្រី ឃួង រ៉ៃ កំពុងរស់នៅក្នុងស្ថានភាពទុក្ខជាន់លើទុក្ខ។** គាត់ធ្លាប់បានដាំបន្លែ ចិញ្ចឹមសត្វ សន្សំប្រាក់ និងថែមទាំងបានខ្ចីប្រាក់បន្ថែមពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទៀតផង។ ក្នុងនាមជាស្ត្រីមេម៉ាយដែលមានពិការភាពម្នាក់ គាត់បានខិតខំតស៊ូរហូតសាងសង់ផ្ទះតូចមួយសម្រាប់រស់នៅជាមួយកូនតូចៗជាទីស្រឡាញ់ទាំងពីរនាក់របស់គាត់។ ប៉ុន្តែ អ្វីៗគ្រប់យ៉ាង បានរលាយបាត់អស់ ត្រឹមតែមួយប៉ព្រិចភ្នែក ញើសឈាមដែលគាត់បានបង្ហូរ និងការខិតខំប្រឹងប្រែងអស់រយៈពេលជិតពាក់កណ្ដាលជីវិត ដោយមិនទាន់ទាំងបានធ្វើពិធីឡើងផ្ទះថ្មីផងនោះ ត្រូវបានកម្ទេចដោយការបាញ់ផ្លោងពីសំណាក់ទាហានថៃ កាលពីចុងខែធ្នូ។ រូបគាត់ និងកូនៗ នៅសល់ត្រឹមតែសេចក្ដីទុក្ខសោកប៉ុណ្ណោះ។ ថ្វីត្បិតតែផ្ទះទាំងមូលបានបាក់ស្រុតក្លាយជាគំនរបាក់បែកទៅហើយក្ដី ក៏អ្នកភូមិដ៏កំសត់រូបនេះមិនទាន់អាចត្រឡប់ទៅផ្ទះវិញបានឡើយ ពីព្រោះទាហានថៃបានដាក់របងបន្លាលួស ដាក់ទូកុងតឺន័រ ឡោមព័ទ្ធតំបន់នោះ និងគ្រប់គ្រងទាំងបំពានលើច្បាប់អន្តរជាតិ[8]។




[7] https://www.facebook.com/reel/4281715815433246
[8] https://www.facebook.com/photo/?fbid=1233582135539514&set=pcb.1233582412206153

**«...ទោះបីជាផ្ទះខ្ញុំក្រយ៉ាងណា ក៏វាជាទីជម្រកដ៏កក់ក្ដៅរបស់ខ្ញុំរហូតដល់ថ្ងៃស្លាប់ដែរ។»**



**ខេត្តបន្ទាយមានជ័យ៖** «អាសូរណាស់កូនអើយ! ពេលម៉ែមកឃើញភ្លាម ម៉ែទន់ដៃជើងអស់ហើយ។ «ទោះបីជាផ្ទះខ្ញុំក្រយ៉ាងណា ក៏វាជាទីជម្រកដ៏កក់ក្ដៅរបស់ខ្ញុំរហូតដល់ថ្ងៃស្លាប់ដែរ» នេះគឺជាសម្ដី របស់លោកយាយ វ៉ាន់ រឿន ដែលបានពោលឡើងទាំងទឹកមុខក្រៀមក្រំ និងសោកសៅជាខ្លាំង បន្ទាប់ពីផ្ទះរបស់គាត់បានបាក់ស្រុត។ លោកយាយ វ៉ាន់ រឿន រស់នៅម្នាក់ឯងក្នុងផ្ទះឈើចាស់មួយ បន្ទាប់ពីស្វាមីរបស់គាត់បានចែកឋានទៅ ហើយកូនៗរបស់គាត់មានគ្រួសារ រៀងៗខ្លួនអស់។ គ្រាប់កាំភ្លើងធំរបស់ថៃបានធ្លាក់មកលើដើមស្វាយដែលមានចម្ងាយប្រហែលមួយម៉ែត្រពីមុខផ្ទះរបស់គាត់។ ផ្ទះដែលជាជម្រកចុងក្រោយរបស់គាត់ត្រូវបានខ្ទាតជាបំណែក គ្រាប់បាញ់ត្រូវរហូតជិតខ្ទេចអស់ទាំងស្រុង។ ក្នុងវ័យជរាទៅហើយ លោកយាយ រឿន មិនអាចរកចំណូលបានច្រើនឡើយ គាត់រស់នៅដោយសារការស៊ីឈ្នួលដកដំឡូងមី និងជួយធ្វើការបន្តិចបន្តួចនៅក្នុងស្រែចម្ការរបស់អ្នកដទៃ។ ផ្ទះរបស់គាត់ស្ថិតនៅក្បែរផ្ទះបីខ្នងទៀត ក្នុងភូមិបែកចានចាស់ ឃុំស្វាយចេក ដែលក៏រងការខូចខាតយ៉ាងធ្ងន់ធ្ងរដោយសារការបាញ់ផ្លោងពីសំណាក់ទាហានសៀមផងដែរ[9]។



**អ្នកស្រី កេង គន្ធា៖ «ខ្ញុំស្អប់សង្គ្រាមណាស់ ព្រោះខ្ញុំរស់នៅជាក្មេងកំព្រាឪពុក តាំងតែពីអាយុ ៥ ឆ្នាំមកម្ល៉េះ។»** ខេត្តបាត់ដំបង៖ គ្រាប់បែក និងគ្រាប់កាំភ្លើងធំដែលបានធ្លាក់រាយប៉ាយនៅតាមតំបន់នានានៃទឹកដីកម្ពុជា បានធ្វើឱ្យអ្នកស្រី កេង គន្ធា មានក្ដីបារម្ភ និងតក់ស្លុតជាខ្លាំង។ ក្ដីរំជើបរំជួលចិត្តរបស់គាត់ កើតចេញពីការដឹងថាកូនៗរបស់គាត់កំពុងរស់នៅ និងបំពេញការងារនៅក្នុងតំបន់ព្រំដែនដ៏គ្រោះថ្នាក់ ដែលកំពុងរងការវាយប្រហារដោយការបាញ់ផ្លោងពីសំណាក់ទាហានថៃ។ ភាពភ័យខ្លាច និងការព្រួយបារម្ភឥតឈប់ឈរចំពោះសុវត្ថិភាពកូនៗ បានបង្ខំឱ្យអ្នកស្រី គន្ធា ទូរសព្ទទៅពួកគេជាបន្ទាន់ ដើម្បីសុំឱ្យពួកគេត្រឡប់មកផ្ទះវិញ និងជួបជុំគ្រួសារឡើងវិញ។

ទឹកចិត្តម្ដាយពិតជាធំធេងណាស់! នេះគឺជាសេចក្ដីស្រឡាញ់របស់ម្ដាយ ដែលតែងតែគិតគូរពីសុខទុក្ខរបស់កូនៗគ្រប់ពេលវេលា។ អ្នកស្រី គន្ធា និងស្វាមី មានកូនចំនួន ៧ នាក់។ កូនស្រីច្បងរបស់គាត់រស់នៅក្នុងស្រុកកំរៀង ខេត្តបាត់ដំបង ចំណែកកូនប្រុសទី ២ រស់នៅ និងធ្វើការក្នុងក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដែលតំបន់ទាំងពីរនេះសុទ្ធតែរងផលប៉ះពាល់ផ្ទាល់ពីការវាយប្រហាររបស់ទាហានថៃ[10]។

[9] https://www.facebook.com/reel/852193187589979
[10] https://www.facebook.com/reel/893976872967514

**«ស្លាយទាំងជីវិត ស្លាយទាំងដំណាំ ស្លាយទាំងមាន់ទា!»**
**អ្នកស្រី ហេង យ៉ែម ត្រូវបានបង្ខំចិត្តរត់ភៀសខ្លួនចេញពីផ្ទះសម្បែងទាំងក្ដីបារម្ភ។**



**ខេត្តពោធិ៍សាត់៖** អ្នកស្រី ហេង យ៉ែម រួមជាមួយគ្រួសារជាច្រើនទៀត បានសម្រេចចិត្តជម្លៀសខ្លួនទៅកាន់ទីតាំងដែលមានសុវត្ថិភាពជាងមុន ដោយសារក្ដីបារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួន។ ការចាកចេញពីផ្ទះទាំងក្ដីស្លន់ស្លោ អ្នកស្រីបានមកបោះជម្រកបណ្ដោះអាសន្ននៅតាមបណ្ដោយផ្លូវជាតិលេខ៥៥ ក្នុងភូមិរកោះ ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ដោយសម្រាកនៅក្នុងតង់ក្រោមដើមឈើ។ ជាក់ស្ដែង ទាហានថៃបានបាញ់ផ្លោងគ្រាប់ធ្លាក់នៅក្នុងតំបន់ទំនប់អូរក្លូកដំរី ក្នុងស្រុកវាលវែង ដែលមានចម្ងាយប្រហែល២០ ទៅ ៣០ គីឡូម៉ែត្រពីកន្លែងដែលគាត់រស់នៅ។ ដោយសារតែភាពភ័យខ្លាច អ្នកស្រី យ៉ែម ត្រូវបានបង្ខំចិត្តចាកចេញពីផ្ទះនៅយប់ថ្ងៃទី១៨ ខែធ្នូ។ អ្នកស្រីយករបស់របរតាមខ្លួនបានតិចតួចបំផុត មានតែសម្លៀកបំពាក់ សម្ភារៈផ្ទះបាយ និងកូនចៅប៉ុណ្ណោះ។ ចំណែកឯដំណាំដំឡូងមីដែលដល់ពេលត្រូវប្រមូលផល ក៏ត្រូវបោះបង់ចោលដែរ ដោយសារតំបន់នោះត្រូវបានគ្របដណ្ដប់ដោយសង្គ្រាម និងការឈ្លានពានពីកម្លាំងទាហានថៃ។ យោងតាមស្ត្រីវ័យ ៦៣ឆ្នាំរូបនេះ ជម្លោះដែលកំពុងបន្តបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជីវភាពរស់នៅរបស់គាត់។ «ខ្ញុំចង់ឱ្យប្រទេសជាតិត្រឡប់មកមានសន្តិភាពដូចដើមវិញ មិនចង់រស់នៅទាំងលំបាកវេទនាដូចសព្វថ្ងៃនេះទេ។ ខ្ញុំចង់ឱ្យសង្គ្រាមនេះបញ្ចប់ទៅឆាប់ៗ» នេះជាការអំពាវនាវរបស់អ្នកស្រី ក្នុងនាមជាអ្នកភូមិរស់នៅតំបន់ប្រមោយ[11]។

**លោកយាយវ័យ ៧៧ឆ្នាំ ពោលទាំងក្ដីព្រួយបារម្ភ និងអំពាវនាវសុំតែសន្តិភាពប៉ុណ្ណោះ បន្ទាប់ពីទាហានថៃបានទម្លាក់គ្រាប់បែកនៅក្បែរភូមិ។**



**ខេត្តឧត្តរមានជ័យ៖** គ្រួសាររាប់សិបនាក់បានរត់ភៀសខ្លួនចេញពីផ្ទះសម្បែងទាំងក្ដីស្លន់ស្លោ បន្ទាប់ពីកម្លាំងទាហានសៀមបានប្រើប្រាស់យន្តហោះចម្បាំងប្រភេទ F-16 ទម្លាក់គ្រាប់បែកចំនួន ២ គ្រាប់ នៅចំណុចស្ពានអូរជីក កាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៥។ ក្នុងចំណោមអ្នកភៀសសឹកទាំងនោះ ក៏មានអ្នកស្រី រ៉ង់ ឡុយ អាយុ ៧៧ឆ្នាំ ដែលបាននាំកូនចៅរត់ទៅពួនតាមមាត់អូរ ដើម្បីគេចពីការទម្លាក់គ្រាប់បែក។ ស្ត្រីវ័យជរារូបនេះ បានដកដង្ហើមធំ ប្រាថ្នាចង់បានសន្តិភាព និងបានសម្ដែងការព្រួយបារម្ភយ៉ាងខ្លាំងចំពោះសុវត្ថិភាពរបស់ក្មេងៗជំនាន់ក្រោយ ដោយគាត់បានរំឭកថា គាត់ធ្លាប់បានឆ្លងកាត់ការឈឺចាប់យ៉ាងធ្ងន់ធ្ងររួចមកហើយក្នុងសម័យសង្គ្រាមស៊ីវិល និងរបប ប៉ុល ពត។ គាត់បានរំឭកទាំងក្ដីសោកសៅថា៖ «ខ្ញុំជួបការលំបាកតាំងពីសម័យ ប៉ុល ពត មកម្ល៉េះ។ ប្ដីរបស់ខ្ញុំត្រូវបានគេយកទៅសម្លាប់នៅក្នុងឆ្នាំ ១៩៧៣ ដែលធ្វើឱ្យខ្ញុំក្លាយជាស្ត្រីមេម៉ាយ និងរស់ក្នុងភាពក្រខ្សត់តាំងពីពេលនោះមក។ ឥឡូវនេះ ក្នុងវ័យជរាទៅហើយ ខ្ញុំបែរជាត្រូវឃើញកូនចៅរត់គេចពីគ្រាប់បែក ខកខានការរៀនសូត្រ និងការបន់ស្រន់

[11] https://www.facebook.com/reel/1901225093809284

មិនខុសពីសម័យមុនឡើយ»។ គួរបញ្ជាក់ផងដែរថា ការទម្លាក់គ្រាប់បែកនេះ បានកើតឡើងនៅស្ពានអូរជីក ដែលជាចំណុចព្រំប្រទល់រវាងស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ និងស្រុកស្រីស្នំ ខេត្តសៀមរាប ដែលបង្កឱ្យមានការភ័យខ្លាចយ៉ាងខ្លាំងដល់ប្រជាពលរដ្ឋដែលរស់នៅក្បែរនោះ[12]។



លោក ដូន ម៉ាប់ និងអ្នកស្រី ស៊ាន សៀម បាននាំគ្នារត់ភៀសខ្លួនទាំងក្ដីស្លន់ស្លោតាមផ្លូវទឹក ដោយប្រើប្រាស់ទូកតូចៗ ដើម្បីគេចចេញពីតំបន់គ្រោះថ្នាក់ក្នុងខេត្តកោះកុង។ ពួកគាត់បានធ្វើដំណើរទៅដល់តំបន់ដែលមានសុវត្ថិភាព បន្ទាប់ពីចាកចេញពីភូមិប៉ាក់ខ្លង ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង ដោយសារតែកម្លាំងទាហានថៃបានបាញ់ផ្លោងគ្រាប់ចេញពីនាវាចម្បាំង សំដៅមកកាន់កោះយ៉ និងឆ្នេរសមុទ្រប៉ាក់ខ្លង។ គ្រួសារទាំងពីរមិនហ៊ានឡើងមកលើគោករកជំរំភៀសខ្លួនឡើយ ដោយសារខ្លាចបាត់បង់ទូក ដែលជាមធ្យោបាយចិញ្ចឹមជីវិតតែមួយគត់សម្រាប់ការនេសាទ។ លោក ម៉ាប់ និងភរិយា គឺអ្នកស្រី សៀម ត្រូវបានបង្ខំចិត្តដេកនៅលើទូកតូចនោះ ដោយគ្មានកន្ទេល ភួយ ឬដំបូលសម្រាប់ការពារខ្យល់អាកាសដ៏ត្រជាក់នៅពេលយប់ឡើយ។ ពួកគេបានរត់ភៀសខ្លួនចេញពីផ្ទះទាំងកណ្ដាលអាធ្រាត្រ ចន្លោះថ្ងៃទី១២ និងថ្ងៃទី១៣ ខែធ្នូ ដោយមិនបានយកអ្វីតាមខ្លួនឡើយ សូម្បីតែទ្វារផ្ទះក៏មិនដឹងថាបានចាក់សោត្រឹមត្រូវឬអត់ផង។ សម្លេងគ្រាប់កាំភ្លើងធំរបស់នាវាចម្បាំងថៃ ដែលបាញ់មកលើតំបន់ឆ្នេរកោះយ៉ និងប៉ាក់ខ្លង បានធ្វើឱ្យអ្នកស្រី សៀម ដែលមានជំងឺប្រចាំកាយស្រាប់ផងនោះ មានការភ័យខ្លាចជាខ្លាំង។ ចំណែកឯលោក ម៉ាប់ ដែលត្រូវបានភរិយាដាស់ឱ្យក្រោកឡើងទាំងកំពុងលង់លក់ក្នុងដំណេក ក៏បានប្រញាប់ប្រញាល់បញ្ឆាទូកសំដៅទៅរកកន្លែងមានសុវត្ថិភាពទាំងប្រផិតប្រផើយ[13]។



លោក ប៉ែន រិទ្ធី ដែលជាមេភូមិជោគជ័យ រួមជាមួយប្រជាពលរដ្ឋដែលផ្លាស់ទីលំនៅផ្សេងទៀត គឺជាអ្នករស់នៅក្នុងភូមិជោគជ័យផ្ទាល់ ទាំងផ្ទះសម្បែងរបស់ប្រជាពលរដ្ឋ និងវត្តអារាមក្នុងមូលដ្ឋានត្រូវបានរងការខូចខាតយ៉ាងធ្ងន់ធ្ងរ ដោយសារការបាញ់ផ្លោងពីសំណាក់ទាហានថៃ។ បន្ទាប់ពីមានបទឈប់បាញ់ កងកម្លាំងថៃថែមទាំងបានវាយរបងបន្លាលួស ដាក់ទូកុងតឺន័រ និងដោតទង់ជាតិរបស់ពួកគេដើម្បីឡោមព័ទ្ធតំបន់នោះដោយខុសច្បាប់។ លើសពីនេះទៅទៀត គ្រាប់យុទ្ធភណ្ឌមិនទាន់ផ្ទុះត្រូវបានបន្សល់ទុក និងរាយប៉ាយពេញផ្ទៃដី ដែលកំពុងបង្កគ្រោះថ្នាក់ជាបន្តបន្ទាប់ដល់ប្រជាពលរដ្ឋរស់នៅទីនោះ[14]។

[12] https://www.facebook.com/reel/2418216758592887
[13] https://www.facebook.com/reel/863597676252418
[14] https://www.facebook.com/reel/3361538710662768

**ប្តីប្រពន្ធមានពិការភាព ត្រូវបានទាហានថៃបណ្តេញចេញពីផ្ទះសម្បែង និងវាយរបងបន្លាលួសរាំងមិនឱ្យត្រឡប់ទៅវិញ។**



**ខេត្តបន្ទាយមានជ័យ៖** លោកយាយ នាង ជឿន និងស្វាមី ដែលមានពិការភាពជើងដូចគ្នា ត្រូវបានទាហានថៃបង្ខំឱ្យចាកចេញពីផ្ទះដែលពួកគេបានរស់នៅអស់រយៈពេលរាប់សិបឆ្នាំមកហើយ។ ប្តីប្រពន្ធដ៏កំសត់នេះ បានត្រឹមតែអង្គុយនៅលើរទេះ សម្លឹងមើលទៅផ្ទះរបស់ខ្លួនដែលឥឡូវនេះត្រូវបានឡោមព័ទ្ធដោយរបងបន្លាលួសរបស់ទាហានសៀម ទាំងក្តីក្តុកក្តួល និងឈឺចាប់ជាពន់ពេក។ «ខ្ញុំមិនដឹងអីសោះ ស្រាប់តែពួកគេ (ទាហានថៃ) បើកឡានមកដល់ វាយបន្លាលួសភ្លាមៗតែម្តង។ បន្ទាប់មក ពួកគេបានដេញពួកខ្ញុំចេញ ដោយប្រាប់ថាដីនេះជារបស់ពួកគេ។ ខ្ញុំស្តាយដីនេះណាស់ ខ្ញុំបានខិតខំកាប់ឆ្ការ និងរុករកមីនចេញពីដីនេះទាំងលំបាក» នេះជាសម្តីរបស់លោកយាយ នាង ជឿន ដែលបានប្រាប់សារព័ត៌មានឌីជីថលមួយ កាលពីថ្ងៃទី១៦ ខែសីហា។ ផ្ទះរបស់ពួកគាត់ស្ថិតនៅក្នុងភូមិព្រៃចាន់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។ នៅក្នុងភូមិនេះ និងនៅចំណុចច្រកទ្វារព្រំដែនជោគជ័យ មានគ្រួសារសរុបចំនួន ១២ គ្រួសារ (ស្មើនឹង ៥៩ នាក់) ត្រូវបានទាហានថៃបណ្តេញចេញពីផ្ទះសម្បែង ដោយពួកគេបានធ្វើរបងព័ទ្ធជុំវិញ និងរាំងមិនឱ្យអ្នកភូមិត្រឡប់ទៅវិញ ចាប់តាំងពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៥ មក[15] ។





[15] https://www.facebook.com/reel/785440297345038

**ខេត្តបន្ទាយមានជ័យ៖** ចាប់តាំងពីចុងខែធ្នូ ឆ្នាំ២០២៥ រហូតមកដល់ថ្ងៃទី៩ ខែមករា ឆ្នាំ២០២៦ កងកម្លាំងថៃបានបន្តរាយរបងបន្លាលួស ដាក់ទូកុងតឺន័រ និងដោតទង់ជាតិរបស់ខ្លួន ដើម្បីឡោមព័ទ្ធ និងរឹបអូសយកផ្ទះសម្បែងរបស់គ្រួសារខ្មែរប្រហែល ៧០០ គ្រួសារ នៅក្នុងភូមិឈូកជ័យ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។ សកម្មភាពឈ្លានពាននេះ បានកើតឡើងនៅក្នុងកំឡុងពេលនៃកិច្ចព្រមព្រៀងបទឈប់បាញ់បណ្ដោះអាសន្នរវាងកម្ពុជា និងថៃ ដែលត្រូវបានធ្វើឡើងកាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥។ លោក ប៉ែន រិទ្ធី មេភូមិជោគជ័យ បានបញ្ជាក់យ៉ាងច្បាស់អំពីស្ថានភាពដ៏តានតឹងនេះ[16]











[16] https://www.facebook.com/reel/1407061871133230



អ្នកស្រី ឃួង រ៉ែ កំពុងស្ថិតក្នុងសេចក្តីទុក្ខវេទនា។ គាត់ធ្លាប់បានដាំបន្លែ ចិញ្ចឹមសត្វ សន្សំប្រាក់ និងថែមទាំងបាន ខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្នុងនាមជាស្ត្រីមេម៉ាយ ដែលមានពិការភាពរាងកាយម្នាក់ គាត់បានខិតខំតស៊ូសាងសង់ផ្ទះដ៏សមរម្យមួយ ដើម្បីរស់នៅជាមួយកូនតូចៗជាទីស្រឡាញ់ទាំងពីរនាក់របស់គាត់។ ប៉ុន្តែ អ្វីៗគ្រប់យ៉ាងបានរលាយបាត់អស់ ត្រឹមតែមួយប៉ព្រិចភ្នែកប៉ុណ្ណោះ។ ញើសឈាមដែលគាត់បានបង្ហូរ និងការខិតខំប្រឹងប្រែងអស់រយៈពេលជិតពាក់កណ្តាលជីវិត ដោយមិនទាន់ទាំងបានធ្វើពិធីឡើងផ្ទះផងនោះ ត្រូវបានកម្ទេចដោយការបាញ់ផ្លោងពីសំណាក់ទាហានថៃ កាលពីចុងខែធ្នូ។

រូបគាត់ និងកូនៗ នៅសល់ត្រឹមតែសេចក្តីសោកសៅប៉ុណ្ណោះ។ ថ្វីត្បិតតែផ្ទះទាំងមូលបានក្លាយជាគំនរបាក់បែកទៅហើយក្តី ក៏អ្នកភូមិឈូកជ័យដ៏កំសត់រូបនេះ មិនអាចត្រឡប់ទៅសាងសង់ឡើងវិញបានឡើយ ពីព្រោះទាហានថៃបានដាក់របងបន្លាលួស ដាក់ទូកុងតឺន័រ និងឡោមព័ទ្ធតំបន់នោះ ដើម្បីគ្រប់គ្រងទាំងបំពានលើច្បាប់អន្តរជាតិ[17]។




បុគ្គលិកអង្គការ ក.ជ.ទ ចុះសួរសុខទុក្ខនៅតាមជំរំភៀសសឹក




17 https://www.facebook.com/share/p/17cYD5h6fG/

## ៣.៣. ការបាញ់ផ្លោងមកលើប្រជាជនស៊ីវិលនៅកម្ពុជា

យ៉ាងហោចណាស់មានអ្នកដំណើរពីរនាក់ ដែលកំពុងធ្វើដំណើរតាមបណ្តោយផ្លូវជាតិលេខ ៥ ក្នុងតំបន់ក្បែរក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ បានរងរបួសដោយសារបំណែកគ្រាប់កាំភ្លើងធំរបស់ទាហានថៃ ដែលបានបាញ់ត្រូវរថយន្តមួយគ្រឿងនៅព្រឹកថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៥។ យោងតាមក្រសួងការពារជាតិ បានឱ្យដឹងថា នៅចន្លោះម៉ោង ៨:១៥ នាទី ដល់ម៉ោង ៨:៣៦ នាទីព្រឹក ថ្ងៃទី២៦ ខែធ្នូ ទាហានថៃបានបាញ់កាំភ្លើងធំចំនួន ៥ គ្រាប់ ចូលមកក្នុងតំបន់សង្កាត់និមិត្ត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។





ប្រជាពលរដ្ឋស៊ីវិលគ្រាន់តែចង់ឈប់សម្រាកនៅលើទឹកដីនៃប្រទេសខ្លួនឯងប៉ុណ្ណោះ ប៉ុន្តែជាអកុសល បែរជាក្លាយជាគោលដៅនៃការវាយប្រហារបែបភេរវកម្ម ដែលបានឆក់យកជីវិតរបស់ពួកគេទៅវិញ។ នៅកន្លែងកើតហេតុដែលមានរថយន្តក្រុងដឹកអ្នកដំណើរពីរគ្រឿង អ្នកបើកបរពីរនាក់ត្រូវបានសម្លាប់យ៉ាងអាណោចអាធ័ម ក្នុងខណ:ពេលដែលពួកគេកំពុងហូបអាហារថ្ងៃត្រង់[18]។






[18] https://www.facebook.com/reel/848963307917115

## ៣.៤. ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចរបស់ពលរដ្ឋខ្មែរតាមជាយដែន



ក្នុងអំឡុងពេលមានជម្លោះព្រំដែន អ្នកស្រី ឡូ សុខភាវ ត្រូវបានបង្ខំចិត្តបោះបង់ចោលផ្ទះសម្បែង និងមុខរបរអាជីវកម្មរបស់ខ្លួន ដើម្បីមកស្នាក់នៅក្នុងជំរំភៀសសឹក។ រហូតមកដល់ពេលនេះ អ្នកស្រីនៅតែមិនទាន់អាចត្រឡប់ទៅផ្ទះវិញបានឡើយ ដោយសារកងទ័ពថៃកំពុងកាន់កាប់ភូមិរបស់គាត់។ ដោយសារមិនអាចរកចំណូលបានទាល់តែសោះ ចាប់តាំងពីខែកក្កដា ឆ្នាំ២០២៥ រហូតដល់ខែមករា ឆ្នាំ២០២៦ មក។ នៅខែកុម្ភៈ ឆ្នាំ២០២៦ នេះ អ្នកស្រីក៏បានបង្កើតគំនិតច្នៃប្រឌិតថ្មីមួយ គឺការធ្វើ «ហាងអ៊ុតសក់ចល័ត» ដើម្បីបម្រើសេវាកម្មដល់អតិថិជនទាំងក្នុង និងក្រៅជំរំភៀសខ្លួន ដើម្បីរកប្រាក់កម្រៃមកទ្រទ្រង់គ្រួសារ[19]។









[19] https://www.facebook.com/reel/1220786380189814

គិតត្រឹមចុងខែមករា ឆ្នាំ២០២៦ ផ្សារអូរស្មាច់ ក្នុងខេត្តឧត្តរមានជ័យ ត្រូវបានបំផ្លិចបំផ្លាញទាំងស្រុងដោយសារជម្លោះ។ ក្រោយពេលបញ្ចប់ការប្រយុទ្ធគ្នា ប្រជាពលរដ្ឋនៅតែមិនទាន់អាចត្រឡប់ទៅប្រកបអាជីវកម្មនៅក្នុងផ្សារនេះវិញបាននៅឡើយ ដោយសារតែការខូចខាតធ្ងន់ធ្ងរ និងវត្តមានគ្រាប់យុទ្ធភណ្ឌមិនទាន់ផ្ទុះ ដែលទាមទារពេលវេលាដើម្បីបោសសម្អាត និងស្តារឡើងវិញ។



ស្ថានភាពអាជីវកម្មរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន មុនពេល និងក្រោយពេលមានវិវាទ នៅក្នុងស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។









## ៣.៥. ផលប៉ះពាល់ពីផ្សែងពុល

កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៥ មន្ត្រីឧទ្យានុរក្ស និងសមាជិកសហគមន៍មូលដ្ឋាន បានរាយការណ៍ថា បានរកឃើញសាកសពមេដំរីមួយក្បាល និងកូនរបស់វា បានងាប់នៅចំណុចអូស្នាច់ ក្នុងដែនជម្រកសត្វព្រៃ «ព្រះរកា-ឆែប»។ យោងតាមការពិនិត្យបឋម មេដំរីដែលមានទម្ងន់ប្រហែល ៥០០ គីឡូក្រាម និងកូនទើបនឹងកើតទម្ងន់ប្រហែល ៨០ គីឡូក្រាម ត្រូវបានរកឃើញថាងាប់នៅក្នុងស្ទឹង។ មេដំរីមានស្លាកស្នាមរបួសដោយសារបំណែកគ្រាប់កាំភ្លើងធំ ឬគ្រាប់បែកដៃរបស់ទាហានសៀម ដែលបណ្ដាលឱ្យរលូតកូន និងឈានដល់ការងាប់ទាំងមេទាំងកូនតែម្ដង[20]។

ភស្តុតាងច្បាស់លាស់បានបង្ហាញថា ការឈ្លានពានរបស់យោធាថៃ មិនត្រឹមតែបង្កការបំផ្លិចបំផ្លាញដល់ជីវិតមនុស្សប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កគ្រោះថ្នាក់ដល់សត្វព្រៃក្នុងតំបន់ការពារ តាមរយៈការបាញ់បោះគ្រប់ប្រភេទ និងការទម្លាក់គ្រាប់បែកពីយន្តហោះចម្បាំង។ ការប្រើប្រាស់អាវុធទំនើបៗ និងការបញ្ចេញផ្សែងពុលទៅក្នុងព្រៃ ដែលសម្លាប់សត្វព្រៃ គឺជាបទល្មើសប្រឆាំងនឹងបរិស្ថាន និងប្រព័ន្ធអេកូឡូស៊ី។ យោធារបស់ពួកគេមិនបានកំណត់គោលដៅឡើយ ដោយបានវាយប្រហារលើប្រជាពលរដ្ឋខ្មែរ មន្ទីរពេទ្យ សាលារៀន ទីសក្ការៈបូជា វត្តអារាម លួចប្លន់ទ្រព្យសម្បត្តិ និងថែមទាំងធ្វើបាបសត្វព្រៃដែលមិនដឹងអីទៀតផង។










Banteay Meanchey province, on December 16, 2025:
- At 07:36 am, the Thai military fired toxic gas into the area of Prey Chan village.
Further detailed information will be provided later as the situation develops.



[20] https://www.facebook.com/watch/?v=1548240959542277




សត្វខ្ទីងឈ្មោលមួយក្បាល ត្រូវបានអ្នកភូមិប្រទះឃើញងាប់នៅក្នុងវាលស្មៅ ក្នុងភូមិអូផ្អាវ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥។ អាជ្ញាធរអភិរក្សសត្វព្រៃ បានចុះទៅដល់ទីតាំងកើតហេតុ ដើម្បីធ្វើការពិនិត្យសាកសពសត្វនោះ[21]។





[21] https://www.facebook.com/photo?fbid=122175815318478627&set=pcb.122175815420478627

សត្វចិញ្ចឹមរបស់ប្រជាពលរដ្ឋ ក៏ត្រូវបានរកឃើញថាងាប់ផងដែរ[22]។





## ៣.៦. ហេដ្ឋារចនាសម្ព័ន្ធបានបំផ្លាញ ការបិនខ្ទប់ និងការបាត់បង់ទ្រព្យសម្បត្តិ

សាលាបឋមសិក្សាតាមន្តសែនជ័យ ត្រូវបានបំផ្លិចបំផ្លាញទាំងស្រុងដោយសារគ្រាប់កាំភ្លើងធំរបស់ទាហានថៃក្នុងអំឡុងពេលសង្គ្រាម ដែលធ្វើឱ្យសិស្សានុសិស្សជាង ២០០ នាក់ បានបាត់បង់ថ្នាក់រៀនដ៏កក់ក្តៅរបស់ពួកគេ ក្នុងវ័យដែលពួកគេកំពុងស្រេកឃ្លានចំណេះដឹង។ បច្ចុប្បន្ន សាលារៀនចំនួន ១៤ នៅតែបន្តបិទទ្វារ ដែលរារាំងមិនឱ្យសិស្សានុសិស្សអាចចូលរៀនបានឡើយ[23]។



[22] https://url-shortener.me/BOR9
[23] https://www.facebook.com/share/p/1BmB9tiqdE/

មណ្ឌលសុខភាពតាមាន់សែនជ័យ ដែលមានទីតាំងនៅជិតប្រាសាទតាមាន់ ក្នុងឃុំគោកមន ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ក៏ត្រូវបានរងការខូចខាតស្ទើរតែទាំងស្រុងផងដែរ ជាលទ្ធផលនៃការបាញ់ផ្លោង និងការទម្លាក់គ្រាប់បែកចំនួនពីរលើកដោយទាហានថៃ[24]។

ក្នុងអំឡុងពេលនៃការប៉ះទង្គិចគ្នានៃវិវាទព្រំដែនកម្ពុជា-ថៃ ក្នុងឆ្នាំ២០២៥ ស្ពានជាច្រើនត្រូវបានខូចខាត ឬបំផ្លិចបំផ្លាញ ជាពិសេសនៅក្នុងខេត្តពោធិ៍សាត់ ឧត្តរមានជ័យ និងសៀមរាប បន្ទាប់ពីមានការវាយប្រហារតាមអាកាស និងការបាញ់កាំភ្លើងធំពីសំណាក់ភាគីថៃ។ ការវាយប្រហារទាំងនេះបានធ្វើឱ្យរំខានដល់ផ្លូវដឹកជញ្ជូន កាត់ផ្តាច់ទំនាក់ទំនងរវាងភូមិករ និងធ្វើឱ្យវិបត្តិមនុស្សធម៌កាន់តែធ្ងន់ធ្ងរឡើង[25]។




ស្ពានអូរជីក ដែលតភ្ជាប់រវាងស្រុកស្រីស្នំ ខេត្តសៀមរាប និងស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ បានរងការខូចខាតយ៉ាងធ្ងន់ធ្ងរ បន្ទាប់ពីយោធាថៃ បានប្រើប្រាស់យន្តហោះចម្បាំងប្រភេទ F-16 ទម្លាក់គ្រាប់បែកចូលមកក្នុងទឹកដីអធិបតេយ្យភាពរបស់កម្ពុជា ក្នុងអំឡុងពេលមានជម្លោះព្រំដែន។ ការទម្លាក់គ្រាប់បែកដោយយន្តហោះចម្បាំង F-16 នេះ បានកើតឡើងកាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៥។ ការបាញ់ប្រហារនេះបានបំផ្លាញស្ពានទាំងស្រុង ដែលស្ពាននេះមានទីតាំងស្ថិតនៅចម្ងាយជាង ៧០ គីឡូក្រាមពីតំបន់ព្រំដែន។ ក្រោយហេតុការណ៍នោះ រចនាសម្ព័ន្ធស្ពានត្រូវបានខ្ទេចខ្ទី ដែលបង្កការលំបាកយ៉ាងខ្លាំងដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋានសម្រាប់ការធ្វើដំណើរ[26]។




---

[24] https://www.facebook.com/photo/?fbid=1338370958331523&set=pcb.1338371718331447

[25] https://www.facebook.com/share/p/1KN7GECZJ8/

[26] https://www.facebook.com/share/p/1GdrUmpqeL/

កងទ័ពថៃបានដំឡើងរបងបន្លាលួស និងដាក់លូទឹកបេតុងចូលមកក្នុងទឹកដីកម្ពុជាជម្រៅជាង ៤០០ ម៉ែត្រ នៅក្បែរច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ បន្ទាប់ពីបទឈប់បាញ់បានចូលជាធរមាននៅត្រង់ម៉ោង ១២ ថ្ងៃត្រង់ កាលពីថ្ងៃទី២៧ ខែធ្នូ ខណៈដែលផ្សារអូរស្មាច់ត្រូវបានរងការបាញ់ផ្លោងដោយកាំភ្លើងធំពីសំណាក់ភាគីថៃ[27] ដែលបណ្ដាលឱ្យប្រជាពលរដ្ឋជាច្រើននាក់ត្រូវបន្តស្នាក់នៅក្នុងជំរំភៀសខ្លួន។








NIKKEI Asia

Log In | Subscribe

World | Trending | Business | Markets | Tech | Politics | Economy | Features | Opinion | Life & Arts | Podcast

THAILAND-CAMBODIA CONFLICT

Cambodia raises annexation fears over Thai land seizures

Barricades, barbed wire and demolished homes show border dispute far from over

CHOUK CHEY, Cambodia -- In this rural corner of western Cambodia, the scars of the country's border war with neighboring Thailand show the damage

[27] https://www.facebook.com/share/p/1BkXHq9jCo/

កងទ័ពសៀមបានយកទូកុងតឺន័រមកដាក់បិទកាត់ផ្លូវជាតិលេខ ៥៨ និងឡោមព័ទ្ធភូមិជោគជ័យ ដែលស្ថិតនៅក្នុងទឹកដីកម្ពុជា បន្ទាប់ពីបទឈប់បាញ់ត្រូវបានអនុវត្តកាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥។ ការដាក់ទូកុងតឺន័រនេះ បានរារាំងមិនឱ្យប្រជាពលរដ្ឋកម្ពុជាអាចធ្វើដំណើរឆ្លងកាត់បានឡើយ។ ផ្លូវជាតិលេខ ៥៨ ដែលជាផ្លូវតភ្ជាប់ពីទីប្រជុំជនដ៏មមាញឹកនៃក្រុងប៉ោយប៉ែត ទៅកាន់ក្រុងសំរោង ខេត្តឧត្តរមានជ័យ ត្រូវបានបិទខ្ទប់ត្រង់ចំណុចបង្គោលឡូ (គីឡូម៉ែត្រ) លេខ ២០-២១ក្បែរភូមិជោគជ័យ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។ ទោះជាយ៉ាងណាក៏ដោយ ផ្លូវវាងមួយទៀតនៅតែអាចប្រើប្រាស់បាន ប៉ុន្តែវាមានចម្ងាយផ្លូវឆ្ងាយជាងមុនបន្តិច។ *(រាយការណ៍នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២៦)*







**សន្តិភាពនៅលើក្រដាស ប៉ុន្តែការផ្លាស់ទីលំនៅគឺជាការពិត៖ ប្រជាជនខ្មែររាប់ពាន់នាក់នៅតែមិនទាន់អាចត្រឡប់ទៅផ្ទះវិញបាន បន្ទាប់ពីបទឈប់បាញ់នៅព្រំដែន។** ទោះបីជាមានការប្រកាសបទឈប់បាញ់លើកទីពីរនៅចុងឆ្នាំ២០២៥ ក៏ដោយ ក៏គ្រួសាររាប់ពាន់នៅក្នុងខេត្តបន្ទាយមានជ័យ នៅតែមិនអាចត្រឡប់ទៅផ្ទះសម្បែងវិញបាន ដោយសារតែវត្តមានគ្រាប់យុទ្ធភណ្ឌមិនទាន់ផ្ទុះ និងការរឹតត្បិតពីសំណាក់កងកម្លាំងទាហានថៃ។ ប្រជាពលរដ្ឋដែលភៀសខ្លួនមកពីតំបន់ជោគជ័យ ព្រៃចាន់ និងបឹងត្រកួន នៅតែបន្តរស់នៅក្នុងតង់ ប្លាស្ទិកបណ្ដោះអាសន្ន តាមមជ្ឈមណ្ឌលសុវត្ថិភាពនានា ដូចជាវត្តចាន់សី និងវត្តកណ្ដាល ដោយត្រូវស៊ូទ្រាំនឹងកម្ដៅថ្ងៃយ៉ាងក្ដៅនាពេលថ្ងៃ និងភាពត្រជាក់នៅពេលយប់។ មនុស្សជាច្រើនបានរត់ភៀសខ្លួនដោយមិនបានយកអ្វីតាមខ្លួនឡើយ ហើយពួកគេនៅតែមានក្ដីបារម្ភយ៉ាងខ្លាំងអំពីការត្រឡប់ទៅកាន់ផ្ទះសម្បែងដែលត្រូវបានបំផ្លិចបំផ្លាញវិញ[28]។





---

[28] https://url-shortener.me/BORU

## ៣.៧. ការប្រើប្រាស់សម្ដីស្អប់ខ្ពើមលើបណ្ដាញសង្គម

ក្នុងអំឡុងពេលមានវិវាទព្រំដែនខ្មែរ-ថៃ បណ្ដាញសង្គមបានក្លាយជាសមរភូមិដ៏សំខាន់សម្រាប់សកម្មភាពអរិភាពនឹងគ្នា។ អ្នកប្រើប្រាស់បណ្ដាញសង្គមនៅកម្ពុជា និងថៃ បានប្រើប្រាស់សម្ដីស្អប់ខ្ពើមយ៉ាងធ្ងន់ធ្ងរ រោហារសាស្ត្រជាតិនិយមជ្រុល និងការបង្ហោះខ្លឹមសារបែបញុះញង់ដែលបានធ្វើឱ្យភាពតានតឹងរវាងប្រទេសទាំងពីរកាន់តែផ្ទុះឡើងខ្លាំង។ បណ្ដាញសង្គមដូចជា Facebook និង Twitter (X) .... បានខ្លាចទៅជាមធ្យាបាយសម្រាប់អ្នកប្រើប្រាស់មួយចំនួនក្នុងការចោទប្រកាន់ ជេរប្រមាថ និងការឃោសនាអវិជ្ជមាន ដែលភាគច្រើនកំណត់គោលដៅលើអត្តសញ្ញាណ វប្បធម៌ និងអធិបតេយ្យភាពជាតិ។

ការរៀបរាប់តាមបណ្ដាញអនឡាញទាំងនេះ មិនត្រឹមតែឆ្លុះបញ្ចាំងពីកំហឹងដែលកើតមានឡើងផ្ទាល់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានជុតបញ្ឆេះឱ្យមានការមិនទុកចិត្តគ្នាកាន់តែខ្លាំង ការរីករាលដាលនៃព័ត៌មានមិនពិត និងការបង្កើនផលប៉ះពាល់ផ្លូវចិត្តលើជម្លោះនេះ ឱ្យកាន់តែធ្ងន់ធ្ងរថែមទៀត។













Education is very important for Khmer people.😂
การศึกษาเป็นสิ่งสำคัญมาก ต่อ ประเทศเขมร
👇
See translation
There are so many stupid people in Khmer.
Yes, we really like it.


Cambodia Classical Dance
Original
Thailand C@py
Khmer On UNESCO 2003
1886-1920s
Khmer Royal ballet Dancer
Khon Thai Drama
2022
Credit to World Societies & Culture


THAI EDUCATION BLINDS HISTORY!
TEACHING HATE, HIDING THE TRUTH
THAILAND LOST LAND 14 TIMES!
CRUSH THE KHMER!
SIAM SUPREME!
BOOSTING WAR... HIDING THE INVASION.


Due to the brutality and aggression of the Thai military,
the Cambodian people continue to boycott and stop using all Thai products.
STOP THAI GOODS!
BOYCOTT
PRODUCTS
NO THAI PRODUCTS


THAILAND
DESTROYING
CAMBODIA


CRUSH THE KHMER ENEMIES!
TAKE BACK OUR LOST LANDS!
We must defend our holy nation!
Support our brave soldiers!
LOYALTY
MONARCHY!
Khmer are traitors!
Down with the Khmer!
VICTORY OVER CAMBODIA!


UNESCO ICH
KHMER's REQUIREMENT
KHOL to UNESCO
Begging
SOURCE :
https://ich.unesco.org/en/
-process-00913...
Overall, Khmer's request is
1. Shortage of teachers in this field. Ask for help from UNESCO.
2. The Ramayana chapter is not complete (Rama, Phraksa, Sita) the heart of the Ramayana story. Ask for help from UNESCO.
3. Ask for UNESCO cultural exchange. By giving a Cambodian teacher to study in neighboring countries.
4. Asking for help from UNESCO for Mask, Costume, Scene, Music
UNESCO


Fake Khmer Dress
Cambodian wanna be Thailand


กัมพูชา หรือ แสกมพูชา?
Scambodia?
94
45
15
3
Bank Pornpongmetta
Foll...
Cambodia's daily lies are beco... more










ក្នុងអំឡុងពេលមានវិវាទព្រំដែនកម្ពុជា-ថៃ ក្នុងឆ្នាំ ២០២៥ មន្ទីរពេទ្យថៃមួយចំនួនបានប្រកាសបដិសេធមិនទទួលព្យាបាលអ្នកជំងឺជាជនជាតិខ្មែរឡើយ។ ប្រព័ន្ធផ្សព្វផ្សាយធំៗរបស់ថៃបានចោទប្រកាន់ ដដែលៗលើអ្នកជំងឺមកពីកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ថាជាអ្នក «សុំការព្យាបាលដោយឥតគិតថ្លៃ» ដោយបង្ហាញរូបភាពពួកគេថាជាអ្នកមកជញ្ជក់យកប្រយោជន៍ពីប្រព័ន្ធថៃទាំសុខភាពរបស់ថៃ។ មន្ទីរពេទ្យនៅតាមព្រំដែនត្រូវបានគេរៀបរាប់ថា កំពុងត្រូវបាន «ត្រួតត្រាដោយជនបរទេស» ខណៈដែលចំណងជើងព័ត៌មានបានផ្សាយដដែលៗនូវការអះអាងថា៖ អ្នកជំងឺបរទេសបានធ្វើឱ្យថៃខាតបង់ថវិកាអស់ ៣០០ លានបាតក្នុងមួយឆ្នាំ[29]។ បន្ថែមពីនេះ ពលករកម្ពុជាក៏ត្រូវបានរងការរើសអើង និងការប្រើអំពើហិង្សាពីសំណាក់ក្រុមជ្រុលនិយម និងអ្នកជាតិនិយមថៃផងដែរ។ ពលកររាប់ពាន់នាក់ត្រូវបានបញ្ជូនត្រឡប់មកប្រទេសវិញ ហើយស្ថានទូតថៃក៏បានផ្អាកដំណើរការផ្តល់ទិដ្ឋាការការងារសម្រាប់ពលរដ្ឋកម្ពុជាទៀតផង។

[29] https://url-shortener.me/BOPY

## ៣.៨. ការបំផ្លិចបំផ្លាញបេតិកភណ្ឌ និងទីសក្ការៈបូជា

ក្នុងអំឡុងពេលមានជម្លោះព្រំដែនកម្ពុជា-ថៃ ទីតាំងវប្បធម៌ និងសាសនាដ៏សំខាន់ៗមួយចំនួនបានរងការបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរ។ ប្រាសាទព្រះវិហារ និងសំណង់បុរាណផ្សេងទៀតនៅក្បែរខ្សែបន្ទាត់ព្រំដែន ត្រូវបានរងការបាញ់ផ្លោងដោយកាំភ្លើងធំ ដែលបណ្តាលឱ្យផ្នែកខ្លះនៃប្រាសាទត្រូវរងការខូចខាត។ ជាមួយគ្នានេះដែរ រូបសំណាកព្រះវិស្ណុ ដែលត្រូវបានកសាងឡើងក្នុងឆ្នាំ២០១៤ នៅតំបន់អានសេះ ខេត្តព្រះវិហារ រួមជាមួយរចនាសម្ព័ន្ធប្រាសាទនៅក្បែរនោះ ក៏រងការបំផ្លិចបំផ្លាញផងដែរ[30]។






ប្រាសាទតាក្របី
ក្របី



រូបសំណាកព្រះវិស្ណុដ៏សក្ការៈ ដែលមានទីតាំងស្ថិតនៅក្នុងទឹកដីកម្ពុជា (កសាងឡើងក្នុងឆ្នាំ ២០១៤) ត្រូវបានរងការបំផ្លិចបំផ្លាញ។



ប្រាសាទព្រៃចាន់ ក្នុងខេត្តបន្ទាយមានជ័យ

---

30 https://www.facebook.com/reel/874064118543347







វិវាទព្រំដែនកម្ពុជា-ថៃ មិនមែនគ្រាន់តែជាបញ្ហាខ្សែបន្ទាត់នៅលើផែនទីប៉ុណ្ណោះទេ ប៉ុន្តែវាគឺជាកេរដំណែលនៃសន្ធិសញ្ញាសម័យអាណានិគម ការប្រជែងអធិបតេយ្យភាព និងមនោគមវិជ្ជាជាតិនិយម។ ចំណុចកណ្តាលនៃជម្លោះទាំងនេះ គឺប្រាសាទព្រះវិហារ ដែលជាទីតាំងនៃមោទនភាពវប្បធម៌ និងជាចំណុចទាញជម្លោះផ្នែកនយោបាយ។ ចាប់តាំងពីសាលក្រមរបស់តុលាការយុត្តិធម៌អន្តរជាតិ (ICJ)[31] ក្នុងឆ្នាំ ១៩៦២ មក ភាពតានតឹងបានផ្ទុះឡើងជាបន្តបន្ទាប់ ជាពិសេសនៅក្នុងឆ្នាំ ២០០៨ នៅពេលដែលការដាក់បញ្ចូលប្រាសាទព្រះវិហារទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូដោយកម្ពុជា បានដុតបញ្ឆេះឱ្យមានការប្រឆាំងពីក្រុមជាតិនិយមនៅក្នុងប្រទេសថៃ។

នៅក្នុងឆ្នាំ ២០២៥ ការប៉ះទង្គិចគ្នាជាថ្មីបានសង្កត់ធ្ងន់ឱ្យឃើញពីភាពផុយស្រួយនៃសន្តិភាព និងភាពងាយរងគ្រោះនៃសហគមន៍ខ្មែរដែលរស់នៅតាមបណ្តោយព្រំដែនដែលមានវិវាទ។ អស់រយៈពេលរាប់ទសវត្សរ៍មកហើយ ប្រជាពលរដ្ឋតាមបណ្តោយព្រំដែនទាំងនេះបានរងគ្រោះយ៉ាងធ្ងន់ធ្ងរពីការផ្លាស់ទីលំនៅ ភាពអសន្តិសុខ និងភាពស្ងប់ស្ងាត់ ដែលរឿងរ៉ាវរបស់ពួកគេត្រូវបានគ្របដណ្តប់បិទបាំងដោយការចរចាការទូត និងការប្រឈមមុខដាក់គ្នាខាងយោធា។ សៀវភៅនេះមានគោលបំណងដាក់សំឡេងរបស់ពួកគេឱ្យស្ថិតនៅចំណុចកណ្តាល ដើម្បីរំលឹកយើងថា នៅពីក្រោយវិវាទព្រំដែននីមួយៗ គឺសុទ្ធតែជាជីវិតមនុស្ស ការចងចាំ និងការតស៊ូដែលទាមទារឱ្យមានការទទួលស្គាល់ និងទទួលខុសត្រូវ។





31 https://www.icj-cij.org/case/45

## ៣.៩. អំពីការឆបោក

គឺជាបញ្ហាសកល វាជានិន្នាការជាតិ និងសកម្មភាពឧក្រិដ្ឋកម្ម! ទោះបីជាមានមតិអន្តរជាតិមួយចំនួន និងការអះអាងរបស់ភាគីថៃ ដោយព្យាយាមបង្ហាញថាវិវាទព្រំដែនកម្ពុជា-ថៃ គឺជា «តំបន់ឆបោក» ក៏ដោយ ក៏ការលើកឡើងបែបនេះបានមើលរំលងទាំងស្រុងនូវតថភាពជាក់ស្តែងនៃទុក្ខវេទនា របស់គ្រួសារខ្មែរដែលរស់នៅតាមបណ្តោយព្រំដែន ដែលជាការពិតមិនអាចប្រកែកបាន។ សម្រាប់គ្រួសារខ្មែរនៅតាមព្រំដែន ជម្លោះនេះមានន័យថាជាការបាត់បង់ជម្រក ការបំផ្លិចបំផ្លាញផ្ទះសម្បែង និងការបាត់បង់បណ្ណកម្មសិទ្ធិដីធ្លីដែលជាប្រភពចំណូលតាំងពីដើមរៀងមករបស់ពួកគេ។

ប្រជាពលរដ្ឋដែលរងគ្រោះទាំងនេះ មិនមែនជាកូនអុកក្នុងល្បែងនយោបាយនោះទេ ពួកគេគឺជាប្រជាពលរដ្ឋសាមញ្ញដែលជីវិតត្រូវជួបការលំបាកដោយសារការប៉ះទង្គិចគ្នាខាងយោធា និងវោហារសាស្ត្រជាតិនិយម។ មនុស្សជាច្រើនបានបាត់បង់ផ្ទះសម្បែង និងដីស្រែចម្ការ ដែលធ្វើឱ្យពួកគេមិនអាចត្រឡប់ទៅរស់នៅលើដីដូនតារបស់ខ្លួនវិញបាន ខណៈដែលអ្នកផ្សេងទៀតនៅតែត្រូវទទួលរងបន្ទុកបំណុលធនាគារ ទោះបីជាគ្មានទ្រព្យសម្បត្តិ ឬមុខរបរសម្រាប់រកប្រាក់មកសងវិញក៏ដោយ។ សម្រាប់សហគមន៍តាមព្រំដែន ជម្លោះនេះមិនមែនជាការឈ្លោះប្រកែកគ្នាផ្នែកនយោបាយឡើយ ប៉ុន្តែវាគឺជាការតស៊ូប្រចាំថ្ងៃដែលពោរពេញដោយការផ្លាស់ទីលំនៅ ភាពច្របូកច្របល់ និងការលំបាកផ្នែកសេដ្ឋកិច្ច។ ការដោះស្រាយដោយយុត្តិធម៌ណាមួយ ត្រូវតែទទួលស្គាល់ការបាត់បង់របស់ពួកគេ និងធានាថាប្រជាពលរដ្ឋសាមញ្ញមិនត្រូវបានយកទៅប្រើប្រាស់ជាឈ្នាន់សម្រាប់វោហារសាស្ត្រជាតិនិយម ឬល្បែងនយោបាយនោះឡើយ។






គិតត្រឹមថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៥ ក្រោមការវាយប្រហារតាមអាកាសរបស់ភាគីថៃមកលើប្រទេសកម្ពុជា បានបណ្តាលឱ្យប្រជាស៊ីវិលខ្មែររហូតដល់ទៅ ៩៥% ទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ[32]។




32 https://www.facebook.com/photo/?fbid=10161561931610938&set=a.10150113412110938

## ៣.១០. សកម្មភាពហិង្សា និងការរឹបអូសទ្រព្យសម្បត្តិ

សកម្មភាពហិង្សា និងការរឹបអូសយកទ្រព្យសម្បត្តិដោយកងទ័ពថៃ ក្នុងអំឡុងពេលមានវិវាទ ត្រូវបានពិពណ៌នាថាជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ដែលធ្វើឱ្យប៉ះពាល់ដល់សន្តិភាព និងស្ថិរភាពនៅក្នុងសហគមន៍ដែលរងគ្រោះ។ របាយការណ៍ជាច្រើនបានគូសបញ្ជាក់ពីករណីដែលកម្លាំងប្រដាប់អាវុធត្រូវបានប្រើប្រាស់ប្រឆាំងនឹងប្រជាស៊ីវិល ដែលបណ្តាលឱ្យមានការគំរាមកំហែង ការបង្ខំឱ្យផ្លាស់ទីលំនៅ និងការរឹបអូសយកទ្រព្យសម្បត្តិ ក៏ដូចជាសម្ភារៈប្រើប្រាស់ផ្សេងៗរបស់ប្រជាពលរដ្ឋខ្មែរ[33]។











[33] https://www.facebook.com/reel/1218046446590991


FB.ปิยะพงษ์ ศรีนาวงค์






CNN International Now · Join
Dara Sovandara · 12h ·
Dear Thai people, If you see this Thai thief army please inform him to bring back the Motor back to Cambodia to where he stole from.
Thank you
16-8440





## ៣.១១. ការបាត់បង់ដែនអធិបតេយ្យភាព

ក្នុងអំឡុងដំណាក់កាលទីពីរនៃជម្លោះព្រំដែនកម្ពុជា-ថៃ ដែលបានឈានដល់កម្រិតធ្ងន់ធ្ងរ នៅចន្លោះថ្ងៃទី៧ ដល់ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៥ បណ្ដាញសង្គមក្នុងប្រទេសកម្ពុជាបានរាយការណ៍ថា កម្ពុជាបានបាត់បង់ការគ្រប់គ្រងលើតំបន់ប្រហែល ជាង៩០កន្លែង នៅតាមបណ្ដោយខ្សែបន្ទាត់ព្រំដែនដែលមានវិវាទ ខណៈដែលមិនទាន់មាន ព័ត៌មានច្បាស់លាស់ណាមួយពីមន្ត្រីរាជរដ្ឋាភិបាលផ្ដល់ជូនអំពីការបាត់បង់នោះឡើយ ហើយក៏មិនអនុញ្ញាតឱ្យមានការសាកសួរអំពីបញ្ហានេះដែរ។

ការបាត់បង់ទាំងនេះត្រូវបានសម្គាល់ដោយការប៉ះទង្គិចគ្នាដោយហិង្សា ការឈ្លានពានរបស់យោធា និងការបង្ខំឱ្យផ្លាស់ទីលំនៅរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ ប្រជាពលរដ្ឋកម្ពុជានៅក្នុងតំបន់ដែលរងផលប៉ះពាល់ បានប្រឈមមុខនឹងការរឹបអូសទ្រព្យសម្បត្តិ ការបំផ្លិចបំផ្លាញមុខរបរចិញ្ចឹមជីវិត និងភាពអសន្តិសុខកាន់តែខ្លាំងឡើង ដែលធ្វើឱ្យឥទ្ធិពលនៃវិបត្តិមនុស្សធម៌កាន់តែជ្រៅទៅ។ ការបាត់បង់ទឹកដីមិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់អធិបតេយ្យភាពរបស់កម្ពុជានៅក្នុងតំបន់ទាំងនោះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យមានភាពតានតឹងរវាងប្រជាជាតិទាំងពីរកាន់តែខ្លាំងឡើង ដែលសង្កត់ធ្ងន់លើតម្រូវការបន្ទាន់សម្រាប់ការចរចាដោយសន្តិវិធី ការកំណត់ខណ្ឌសីមាព្រំដែនឱ្យបានច្បាស់លាស់ និងការសម្របសម្រួលពីអន្តរជាតិ ដើម្បីបង្ការការរីករាលដាលនៃជម្លោះ និងការពារជីវិតប្រជាជនស៊ីវិល[34]។




[34] https://www.facebook.com/reel/1598251977906107


ភូមិជោគជ័យ
ភូមិព្រៃចាន់
ផ្ទះបីខ្នង
អូភ្លុកដំរី
តំបន់ចរ១
ថ្មដារ
ភ្នំទ្រព្យ
ថ្មដូន
អូស្មាច់
ភ្នំអូប៉ោយ និងអូខ្លាឃ្មុំ
ច្រកបឹងត្រកួន
ភ្នំ៤០០
ផ្ទះតាម៉ុក
អូផ្កាស្នេហ៍
តាថាវ
ជុបអង្គុញ
ចូកគ្រួស
បុសស្បូវ
ដើមត្រាង


ដីណាក់ស្តេច

តាសឹម កំពូលភ្នំ

ចាក់ច្រែង កំពូលភ្នំ

ថ្មពាជុំ កំពូលភ្នំ

ភ្នំរើម

ភ្នំបក្សីចាំក្រុង

តំបន់កអណ្តើក

ភ្នំគីង្គក់

តំបន់កសេះ





ក្រុមប្រឹក្សាសន្តិភាព ដែលផ្តួចផ្តើមឡើងដោយប្រធានាធិបតីអាមេរិក Donald Trump បានបើកកិច្ចប្រជុំលើកដំបូងនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៦ នៅវិទ្យាស្ថានសន្តិភាពអាមេរិក Donald J. Trump ក្នុងទីក្រុង Washington, D.C. សម័យប្រជុំដំបូងនេះ គឺជាការចាប់ផ្តើមជាផ្លូវការនៃអាណត្តិរបស់ក្រុមប្រឹក្សាភិបាល ដែលត្រូវបានអនុម័តដោយដំណោះស្រាយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិក្នុងខែវិច្ឆិកា ឆ្នាំ២០២៥ ។ ពីមេដឹកនាំពិភពលោក រួមទាំងលោក ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីកម្ពុជា។

ក្នុងបទសម្ភាសន៍ផ្តាច់មុខជាមួយ Reuters ក្នុងពេលចូលរួមកិច្ចប្រជុំ "ក្រុមប្រឹក្សាសន្តិភាព" ដែលរៀបចំដោយលោក Trump ក្នុងខែកុម្ភៈ ឆ្នាំ២០២៦ លោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត បានលើកឡើងពីការព្រួយបារម្ភអំពីការលុកលុយយ៉ាងជ្រៅចូលក្នុងទឹកដីកម្ពុជាដោយទាហានថៃ[35]។

*"ទាហានថៃបានចូលឈ្លានពានកាន់តែជ្រៅចូលក្នុងទឹកដីកម្ពុជាជាច្រើនកន្លែង ហើយពួកគេបានហួសពីបន្ទាត់ព្រំដែនដែលថៃទាមទារជាឯកតោភាគី។"*

ប្រឈមមុខនឹងសារព័ត៌មានអន្តរជាតិ លោកនាយករដ្ឋមន្ត្រីបានបំភ្លឺថា៖ «នេះមិនមែនជាការចោទប្រកាន់ទេ ប៉ុន្តែជាស្ថានភាពជាក់ស្តែងនៅទីតាំងមូលដ្ឋាន»។[36]




[35] https://www.reuters.com/world/asia-pacific/cambodian-pm-says-thailand-occupying-territory-after-trump-brokered-ceasefire-2026-02-18/?utm_medium=Social&utm_source=Facebook&fbclid=IwY2xjawQI6VtleHRuA2FlbQIxMABicmlkETJDNWY2YndQRDVBZHdBVUNrc3J0YwZhcHBfaWQQMjIyMDM5MTc4ODIwMDg5MgABHmNRd09GZpQ9SbwrMrtncVnVtRIPNr10tqS6ssrHClury5oWf2Tl51F9Eooo_aem_pqh3DtMNqZJz4pXGBiNhtQ&utm_medium=Social&utm_source=Facebook

[36] https://www.facebook.com/reel/1304425758182903

# ៤. ទស្សនៈយល់ឃើញចំពោះជម្លោះធំៗទាំងពីរក្នុងឆ្នាំ ២០២៥

បន្ទាប់ពីមានជម្លោះធំៗចំនួនពីរលើកក្នុងឆ្នាំ ២០២៥ ប្រជាពលរដ្ឋនៅតាមបណ្ដោយព្រំដែននៅតែបន្តស្ថិតក្នុងស្ថានភាពមិនច្បាស់លាស់ និងរង្គោះរង្គើយ៉ាងខ្លាំង។ គ្រួសារជាច្រើនដែលបានបាត់បង់ផ្ទះសម្បែងក្នុងអំឡុងពេលប៉ះទង្គិចគ្នា នៅតែមិនទាន់អាចត្រឡប់ទៅវិញបានឡើយ ដោយសារភូមិករទាំងមូលត្រូវបានបំផ្លិចបំផ្លាញ ឬប្រែក្លាយជាតំបន់ដែលមិនមានសុវត្ថិភាព។ ការផ្លាស់ទីលំនៅបានធ្វើឱ្យប្រជាពលរដ្ឋត្រូវរស់នៅបែកបាក់គ្នាតាមជម្រកបណ្ដោះអាសន្ន ដោយរង់ចាំតែជំនួយសង្គ្រោះ និងមានភាពស្រពិចស្រពិលចំពោះវាសនានៅថ្ងៃអនាគត។ សូម្បីតែអ្នកដែលព្យាយាមស្នាក់នៅបន្ត ក៏ត្រូវរស់នៅក្នុងបរិយាកាសដ៏តានតឹង ខណៈដែលពាក្យចចាមអារ៉ាមអំពីលទ្ធភាពនៃជម្លោះជុំទីបី បានក្លាយជាបន្ទុកផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរដល់សហគមន៍ បង្កឱ្យមានក្ដីបារម្ភ និងការមិនទុកចិត្តគ្នា។ សកម្មភាពប្រចាំថ្ងៃដូចជា ការធ្វើស្រែចម្ការ ការជួញដូរ និងការសួរសុខទុក្ខសាច់ញាតិដែលត្រូវឆ្លងកាត់ព្រំដែន ត្រូវបានកាត់ផ្ដាច់ ហើយអារម្មណ៍អសន្តិសុខបានធ្វើឱ្យចុះខ្សោយដល់សាមគ្គីភាពក្នុងសង្គម។

វិវាទព្រំដែននេះបានបង្ហាញឱ្យឃើញនូវអារម្មណ៍ចម្រុះភាព រវាងភាពភ័យខ្លាច កំហឹង និងសេចក្ដីសោកសង្រេង។ មនុស្សជាច្រើនបានសម្ដែងការខកចិត្តយ៉ាងខ្លាំងដែលប្រាសាទដ៏សក្ការៈ និងបេតិកភណ្ឌវប្បធម៌ត្រូវបានរងការខូចខាត ដោយពួកគេចាត់ទុកថា វាមិនត្រឹមតែជាការបាត់បង់ប្រវត្តិសាស្ត្រប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាការវាយប្រហារលើអត្តសញ្ញាណជាតិផងដែរ។ គ្រួសារដែលរស់នៅក្បែរតំបន់ជម្លោះ បានរៀបរាប់ពីអារម្មណ៍អសន្តិសុខ ការបាត់បង់ទីលំនៅ និងការលំបាកផ្នែកសេដ្ឋកិច្ច ដោយសារការធ្វើស្រែចម្ការ មុខរបរ អាជីវកម្ម និងជីវភាពរស់នៅប្រចាំថ្ងៃរងនូវការរំខាន ការភ័យខ្លាចដែលនៅតែបន្តកើតមានអំពីអំពើហិង្សាជាថ្មី បានធ្វើឱ្យការស្ដារឡើងវិញនូវជីវភាពមានសភាពយឺតយ៉ាវ ហើយប្រជាពលរដ្ឋនៅតែបន្តរស់នៅជាមួយទាំងការបាត់បង់ទ្រព្យសម្បត្តិរូបវន្ត និងវិបត្តិផ្លូវចិត្តដ៏ឈឺចាប់។

**សំណូមពរ និងដំណោះស្រាយ៖**

- ✓ **ការដោះស្រាយដោយសន្តិវិធី៖** ជម្រុញឱ្យរដ្ឋាភិបាលនៃប្រទេសទាំងពីរដោះស្រាយវិវាទតាមរយៈការសន្ទនា និងការចរចា ជាជាងការប្រឈមមុខដាក់គ្នាដោយអាវុធ។
- ✓ **ការគាំទ្រផ្នែកមនុស្សធម៌៖** ផ្ដល់ការថែទាំសុខភាព ស្បៀងអាហារ សម្ភារៈប្រើប្រាស់ និងជម្រកសម្រាប់គ្រួសារជនភៀសសឹក។
- ✓ **ការគាំទ្រដល់សហគមន៍រងគ្រោះ៖** ស្នើសុំជំនួយមនុស្សធម៌ ការព្យាបាលវេជ្ជសាស្ត្រ និងការកសាងឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធដែលខូចខាត ដូចជាមណ្ឌលសុខភាព សាលារៀន..។
- ✓ **ការជួសជុលហេដ្ឋារចនាសម្ព័ន្ធ៖** កសាងមន្ទីរពេទ្យ ផ្លូវថ្នល់ និងសម្ភារៈបរិក្ខារសហគមន៍ឡើងវិញ ដែលត្រូវបានបំផ្លាញក្នុងអំឡុងពេលប៉ះទង្គិចគ្នា។
- ✓ **ការការពារបេតិកភណ្ឌ៖** អំពាវនាវឱ្យមានការការពារឱ្យបានរឹងមាំនូវប្រាសាទ រូបសំណាក និងទីតាំងវប្បធម៌នានា ដែលជាតំណាងឱ្យអរិយធម៌ខ្មែរ។
- ✓ **កិច្ចសហប្រតិបត្តិការប្រកបដោយសន្តិភាព៖** ជម្រុញឱ្យរដ្ឋាភិបាលទាំងពីរផ្ដល់អាទិភាពលើការផ្សះផ្សា ដើម្បីឱ្យកិច្ចខិតខំប្រឹងប្រែងស្ដារឡើងវិញអាចដំណើរការទៅបាន ដោយមិនមានជម្លោះសារជាថ្មី។
- ✓ **ការចូលរួមពីអន្តរជាតិ៖** មតិខ្លះបានលើកទឹកចិត្តឱ្យអង្គការយូណេស្កូ (UNESCO) និងអង្គការសកលលោកនានា ជួយតាមដាន ឃ្លាំមើល និងថែរក្សាទីតាំងបេតិកភណ្ឌកម្ពុជា។

# ៥. ប្រវត្តិសង្ខេបនៃការបាត់បង់

ប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ត្រូវបានសម្គាល់ ដោយការងើបឡើងនៃអាណាចក្រខ្មែរ ការឈ្លានពានដដែលៗពីមហាអំណាចជិតខាង (ថៃ វៀតណាម និងអាណានិគមបារាំង) និងជម្លោះផ្ទៃក្នុងដ៏ខ្វេចខ្វីក្រោមរបបខ្មែរក្រហមក្នុងទសវត្សរ៍ឆ្នាំ ១៩៧០។ ការឈ្លានពាន និងសង្គ្រាមទាំងនេះហើយ ដែលបានកំណត់រូបរាងព្រំដែន នយោបាយ និងសង្គមរបស់កម្ពុជារហូតមកដល់បច្ចុប្បន្ន។

**សម័យបុរាណ និងមជ្ឈិមសម័យ៖**

- **អាណាចក្រនគរភ្នំ និងចេនឡា (សតវត្សទី១–៨)៖** ជាបណ្តារាជធានីដំបូងៗដែលបានចាក់គ្រឹះនៃអរិយធម៌ខ្មែរ។
- **អាណាចក្រខ្មែរ (ឆ្នាំ ៨០២–១៤៣១)៖** ក្នុងសម័យកាលដ៏រុងរឿងបំផុត អាណាចក្រនេះបានគ្រប់គ្រងដែនដីភាគច្រើននៃអាស៊ីអាគ្នេយ៍ដីគោក។ ប្រាសាទអង្គរវត្តត្រូវបានកសាងឡើងក្នុងសម័យកាលនេះ។
- សង្គ្រាមញឹកញាប់ជាមួយអាណាចក្រ**ចម្ប៉ា** និង**ដាយវៀត** (វៀតណាម)។
- ការឈ្លានពានពី**សំណាក់សៀម** (ថៃ) ក្នុងសតវត្សទី១៤–១៥ បានធ្វើឱ្យអាណាចក្រអង្គរចុះខ្សោយ។
- **ការដួលរលំនៃអង្គរ (ឆ្នាំ ១៤៣១)៖** សម្គាល់ដោយការវាយយកបានពីសំណាក់សៀម ដែលបង្ខំឱ្យរាជធានីរបស់កម្ពុជាត្រូវផ្លាស់ទីមកភាគខាងត្បូង។

**ជម្លោះដើមសម័យទំនើប៖**

- **សតវត្សទី១៦–១៨៖** កម្ពុជាបានក្លាយជាកូនអុកនៅក្នុងការដណ្តើមឥទ្ធិពលគ្នារវាងសៀម (ថៃ) និង វៀតណាម។
- **សង្គ្រាមសៀម-កម្ពុជា៖** ការឈ្លានពានដដែលៗបានបណ្តាលឱ្យមានការបាត់បង់ទឹកដីជាបន្តបន្ទាប់។
- **ការត្រួតត្រារបស់វៀតណាម៖** ត្រឹមសតវត្សទី១៩ វៀតណាមបានគ្រប់គ្រងខេត្តភាគខាងកើតភាគច្រើនរបស់កម្ពុជា។

**សម័យអាណានិគមបារាំង៖**

- **អាណាព្យាបាលបារាំង (ឆ្នាំ ១៨៦៣–១៩៥៣)៖** ព្រះបាទនរោត្តមបានស្វែងរកការការពារពីបារាំង ដើម្បីគេចផុតពីការត្រួតត្រារបស់សៀម និងវៀតណាម។
- កម្ពុជាបានក្លាយជាផ្នែកមួយនៃសហភាពឥណ្ឌូចិនរបស់បារាំង ដោយមានខ្សែបន្ទាត់ព្រំដែនត្រូវបានកំណត់យ៉ាងទូលំទូលាយតាមរយៈសន្ធិសញ្ញាសម័យអាណានិគម។
- **ការត្រួតត្រារបស់ជប៉ុន (ឆ្នាំ ១៩៤១–១៩៤៥)៖** ការគ្រប់គ្រងក្នុងរយៈពេលខ្លីមួយក្នុងអំឡុងសង្គ្រាមលោកលើកទី២។

**ឯករាជ្យភាព និងសង្គ្រាមត្រជាក់៖**

- **ឯករាជ្យភាព (ឆ្នាំ ១៩៥៣)៖** កម្ពុជាបានដណ្តើមយកអធិបតេយ្យភាពជាតិមកវិញពីប្រទេសបារាំង ក្រោមព្រះរាជកិច្ចដឹកនាំរបស់ព្រះបាទនរោត្តម សីហនុ។
- **ឥទ្ធិពលនៃសង្គ្រាមវៀតណាម៖** កម្ពុជាត្រូវបានទាញចូលទៅក្នុងជម្លោះក្នុងតំបន់។

- **ការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក (ឆ្នាំ ១៩៦៩–១៩៧៣)៖** គោលដៅគឺសំដៅលើជម្រករបស់ខ្មែរក្រហម និងវៀតណាមខាងជើង ដែលបានបង្កការបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរដល់តំបន់ជនបទនៃប្រទេសកម្ពុជា។
- **រដ្ឋប្រហារឆ្នាំ ១៩៧០៖** លោកសេនាប្រមុខ លន់ នល់ បានទម្លាក់ព្រះសីហនុ ដែលឈានទៅដល់ការផ្ទុះសង្គ្រាមស៊ីវិល។

**សម័យខ្មែរក្រហម (ឆ្នាំ ១៩៧៥–១៩៧៩)៖**

- **កម្ពុជាប្រជាធិបតេយ្យរបស់ ប៉ុល ពត៖** របបកុម្មុយនីស្តជ្រុលនិយម។
- **អំពើឃោរឃៅ៖** ប្រជាជនកម្ពុជាប្រហែល ១,៧ ទៅ ២ លាននាក់ បានបាត់បង់ជីវិតដោយសារការសម្លាប់រង្គាល ការបង្អត់អាហារ និងការបង្ខំឱ្យធ្វើការងារធ្ងន់ធ្ងរ។
- **ការវាយលុករបស់វៀតណាម (ឆ្នាំ ១៩៧៨–១៩៧៩)៖** បានផ្តួលរំលំរបបខ្មែរក្រហម និងបង្កើតឱ្យមានសាធារណរដ្ឋប្រជាមានិតកម្ពុជា។

**ជម្លោះក្រោយសម័យខ្មែរក្រហម៖**

- **ការបះបោរ៖** ក្រុមខ្មែរក្រហមបានបន្តធ្វើសង្គ្រាមទ័ពព្រៃរហូតដល់ទសវត្សរ៍ឆ្នាំ ១៩៩០។
- **កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ឆ្នាំ ១៩៩១៖** បានបញ្ចប់សង្គ្រាមរាប់ទសវត្សរ៍ និងនាំមកនូវកងកម្លាំងរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ (អ៊ុនតាក់ - UNTAC)។
- **ព្រឹត្តិការណ៍ឆ្នាំ ១៩៩៧៖** សម្តេចតេជោ ហ៊ុន សែន បានពង្រឹងអំណាចដឹកនាំ។
- **វិវាទព្រំដែន៖** ភាពតានតឹងដែលកំពុងបន្តជាមួយប្រទេសថៃ ជាពិសេសជុំវិញប្រាសាទព្រះវិហារ (សាលក្រមតុលាការ ICJ ឆ្នាំ ១៩៦២ និងការប៉ះទង្គិចគ្នាក្នុងឆ្នាំ ២០០៨)។

**ចំណុចសំខាន់ៗដែលគួរកត់សម្គាល់៖**

- ប្រវត្តិសាស្ត្ររបស់កម្ពុជាត្រូវបានកំណត់ដោយ ការឈ្លានពានពីខាងក្រៅ (ថៃ វៀតណាម បារាំង ជប៉ុន សហរដ្ឋអាមេរិក) និងជម្លោះផ្ទៃក្នុង (អំពើប្រល័យពូជសាសន៍ខ្មែរក្រហម)។
- ទោះបីជាមានភាពចលាចលអស់ជាច្រើនសតវត្សរ៍ក៏ដោយ ក៏កម្ពុជាបានខិតខំកសាងប្រទេសឡើងវិញ ទោះបីជាវិវាទព្រំដែន និងការតស៊ូផ្នែកនយោបាយនៅតែជាផ្នែកមួយនៃអត្តសញ្ញាណសម័យទំនើបរបស់ខ្លួនក៏ដោយ។









បុគ្គលិក ACT បានទៅសួរសុខទុក្ខនៅជម្រកជនភៀសសឹក និងផ្តល់ជំនួយមនុស្សធម៌ នៅខែសីហា និងខែធ្នូ ឆ្នាំ២០២៥ នៅខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ និងខេត្តសៀមរាប។











អង្គការក្រុមការងារដើម្បីដោះស្រាយទំនាស់ (កដទ) មានការព្រួយបារម្ភណ៍យ៉ាងខ្លាំងចំពោះជម្លោះនៅតាមបណ្តោយជាយដែលខ្មែរ ថៃ ដែលអូសបន្លាយពីខែកក្កដា-ធ្នូ ឆ្នាំ២០២៥ ដែលបណ្តាលអោយមានប្រជាពលរដ្ឋស្លាប់ រងរបួស និងរត់ចោលផ្ទះសំបែង ខាតបង់នូវទ្រព្យសម្បត្តិ ពេលវេលា ការរៀនសូត្រ..។ល។ កដទ សូមអំពាវនាវដល់ថ្នាក់ដឹកនាំគ្រប់រូប ចូលរួមបញ្ឈប់ហិង្សា និងផ្តល់សុខ សុវត្ថិភាព សន្តិភាពដល់មនុស្សជាតិ។
ACT is deeply concerned on the dispute along Khmer-Thai border, continue since July-December 2025 that cause many people died, injures, displace, lost their property, time and education...etc. ACT would call to all leaders to stop violence and bring safe, security and peace to all.
For Humanitarian
join us!
ACT
Alliance for Conflict Transformation Organization
For International & Local Transfer:
1. Account Name: ACT
2. Name and Address of Bank: # 61,Preah Monivong Blvd,Sangkat Srah Chork,Khan Daun Penh.Phnom Penh, Cambodia.
3. S.W.I.F.T.-Code: ACLBKHPP
4. Route of transfer to be used
5. Bank Account No: 0001-20-229350-1-0
ACT











